លេខ៩
ឆ្នាំ២០២០

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



# បុព្វកថា

ឆ្នាំ ២០២០ នេះ គឺជាពេលវេលាដ៏តានតឹងបំផុតដែលពិភពលោកទាំងមូលកំពុងប្រយុទ្ធនឹងជំងឺផ្លូវដង្ហើមដ៏កាចសាហាវ ដែលមានឈ្មោះថា កូវីដ-១៩។ គ្រប់ប្រទេសទាំងអស់ រួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ បាននិងកំពុងខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩ ដើម្បីធានាឱ្យបាននូវសុខសុវត្ថិភាពទាំងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសុខភាពសាធារណៈ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវវិធានការថ្មីៗបន្ទាន់ជាច្រើន ដើម្បីទប់ស្កាត់ និងស្តារបញ្ហាសេដ្ឋកិច្ចដែលបណ្តាលមកពីកត្តាជំងឺរាតត្បាតសកលនេះ។

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយនឹងលទ្ធផលល្អប្រសើរកន្លងមក តាមរយៈកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាមូលដ្ឋានចម្បងធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា មានលទ្ធភាពក្នុងការដោះស្រាយនូវវិបត្តិជាយថាហេតុនេះជូនប្រជាពលរដ្ឋកម្ពុជាក្រីក្រ និងដាក់ចេញនូវវិធានការនានាជាច្រើន ដើម្បីសម្របសម្រួល បន្ធូរបន្ថយភាពតានតឹង និងលើកស្ទួយស្ថានភាពអាជីវកម្មជាពិសេសសហគ្រាស ធុនតូចនិងមធ្យម ឱ្យល្អប្រសើរក្នុងអភិក្រមប្រុងប្រយ័ត្នខ្ពស់។ លើសពីនេះ គ្រប់ក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាល បានចូលរួមយ៉ាងសកម្មក្នុងយុទ្ធនាការទាំងនេះ តាមរយៈការធ្វើវិចារណកម្មថវិកា និងការបង្កើនប្រសិទ្ធភាព ឱ្យកាន់តែខ្ពស់ក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកាជាតិ។

ការឆ្ពោះទៅមុខរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅបន្តដំណើរការជាធម្មតា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់កម្ពុជា រក្សាបាននូវលំនឹងល្អប្រសើរ និងបន្តកំណើនសេដ្ឋកិច្ច ដោយពុះពារ និងប្រយុទ្ធប្រឆាំងនឹងវិបត្តិជំងឺសកល កូវីដ-១៩ នេះ រួមគ្នាជាមួយពិភពលោកទាំងមូល។

ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា កំពុងឈានដល់ឆ្នាំចុងក្រោយ នៃដំណាក់កាលទី ៣ គឺ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ហើយត្រូវបន្តធ្វើការវាយតម្លៃ ដើម្បីបន្តបោះជំហានទៅរកដំណាក់កាលទី ៤ គឺគណនេយ្យភាពសមិទ្ធកម្មបន្តទៀត។ តាមរយៈសមិទ្ធផលដ៏ល្អប្រសើរកន្លងមកនេះ បានឆ្លុះបង្ហាញឱ្យឃើញថា សមត្ថភាពនៃការរៀបចំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង-ស្ថាប័ន បានបន្តកើនឡើងជាលំដាប់ ដែលជាកត្តាកំណត់ជោគជ័យមួយដ៏សំខាន់ ក្នុងការធានាបាននូវកិច្ចដំណើរការជាបន្តបន្ទាប់។ ការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីសារៈប្រយោជន៍នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគ្រប់ស្រទាប់វណ្ណៈ ទាំងមន្ត្រីរាជការ សិស្ស-និស្សិត ប្រជាពលរដ្ឋ និងសាធារណជនទូទៅ កាន់តែមានការកើនឡើងប្រកបដោយផ្លែផ្កាគួរឱ្យកត់សម្គាល់ផងដែរ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ និងបន្តគាំទ្រទាំងក្នុងទិដ្ឋភាពបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យប្រព្រឹត្តទៅដោយរលូន និងមានសន្ទុះល្អទៅមុខ, ក្រសួង-ស្ថាប័នដែលជាតួអង្គចូលរួមយ៉ាងសកម្មក្នុងការរៀបចំ និងអនុវត្ត, ព្រមទាំងសហសេវិកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**)។

ខ្ញុំសូមបន្តលើកទឹកចិត្តជូនគ្រប់ក្រសួង-ស្ថាប័នចូលរួមអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យកាន់តែខ្លាំងឡើង

ស្របពេលជាមួយគ្នានេះ គឺត្រូវបង្កើនសមត្ថភាព និងឆន្ទៈ គ្រប់កាលៈទេសៈ ដើម្បីចូលរួមជាមួយគ្នា ក្នុងការសម្រេចឱ្យបាននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា ៕

ថ្ងៃ ពុធ ២កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**



# អារម្ភកថា

ក្នុងស្ថានភាពដែលកម្ពុជា កំពុងជួបវិបត្តិដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ ក្នុងរយៈកាល ១ ឆមាសកន្លងមកនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកទ្រទ្រង់ស្ថានភាពសេដ្ឋកិច្ច ឱ្យមានលំនឹង និងអាចគ្រប់គ្រងបាន។

ជាការពិត យើងបាននិងកំពុងបោះជំហានជិតមកដល់ឆ្នាំចុងក្រោយនៃដំណាក់កាលទី ៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២០១៥-២០២០) ហើយឆន្ទៈ និងការពុះពារ របស់គ្រប់តួអង្គពាក់ព័ន្ធនៅតាមក្រសួង- ស្ថាប័ននៅបន្តដោយឥតរួញរា ។ ជាក់ស្តែង អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានសម្របសម្រួលកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាព នៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ ២០១៩។ សមិទ្ធផលការងារក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ តែងតែត្រូវបានផ្សព្វផ្សាយដើម្បីជាសារៈប្រយោជន៍ជូនមន្ត្រីរាជការ និងសាធារណជន តាមរយៈមធ្យោបាយផ្សេងៗ ដូចជាតាមរយៈគេហទំព័រស្ថាប័ន សិក្ខាសាលា វីដេអូ និងឧបករណ៍ផ្សព្វផ្សាយផ្សេងៗទៀត។ ដោយឡែក សម្រាប់ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខ ៩ នេះ ក៏នឹងរំលេចអំពីព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមានឡើងក្នុងរយៈពេលថ្មីនេះ អត្ថបទល្អៗជាច្រើនដែលត្រូវបានចូលរួមរៀបចំដោយក្រុមការងារកែទម្រង់តាមអង្គភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង- ស្ថាប័ន និងគ្រប់ផ្នែក នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ផងដែរ។

ខ្ញុំជឿជាក់ថាព្រឹត្តបត្រនេះនឹងជាចំណែកមួយក្នុងការគាំទ្រចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈការបញ្ជ្រាបការយល់ដឹងដល់សាធារណជនគ្រប់ស្រទាប់វណ្ណៈ ជាពិសេសសាធារណជនដែលមានបំណងចង់យល់ដឹងបន្ថែមអំពីបច្ចុប្បន្នភាពនៃដំណើរការគ្រប់គ្រងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល៕

ថ្ងៃ អង្គារ ១កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០២០

**អគ្គលេខាធិការ**

**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

*ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - លេខ៩ - ឆ្នាំ២០២០*


## ព្រឹត្តិការណ៍

**ទំព័រទី ០១**
កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអំពីវឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ទំព័រទី ០៤**
កិច្ចប្រជុំអនុម័តផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រចំនួន ៣ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)

**ទំព័រទី ០៧**
ពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន ១៧ និងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣"

## អត្ថបទ

**ទំព័រទី ០៩**
វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣

**ទំព័រទី ១៣**
វិធានការចំពោះមុខប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩

**ទំព័រទី ១៥**
ការផ្សារភ្ជាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសេវាសាធារណៈ

**ទំព័រទី ១៨**
ដំណើរឆ្ពោះទៅប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម

**ទំព័រទី ២១**
ការដាក់អនុវត្តនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS

**ទំព័រទី ២៤**
អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ

**ទំព័រទី ២៦**
ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្ត យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥

**ទំព័រទី ២៨**
វិធីសាស្ត្រវាយតម្លៃប្រសិទ្ធភាពរបស់រដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ឧបករណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធ TADAT

**ទំព័រទី ៣១**
មុខងារសវនកម្មផ្ទៃក្នុង និងសមិទ្ធផលសំខាន់ៗ

**ទំព័រទី ៣៣**
ច្បាប់រៀបចំអង្គការ÷កសាងទស្សនាទាន ឆ្ពោះទៅពង្រឹងប្រព័ន្ធ

## សុន្ទរកថា

**ទំព័រទី ៣៧**
សុន្ទរកថា ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS

## ទស្សនៈ និងមតិ

**ទំព័រទី ៤១**
ប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

**ទំព័រទី ៤១**
ប្រសាសន៍ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ កម្មវិធីឧបត្ថម្ភ សាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

**ទំព័រទី ៤២**
ប្រសាសន៍ឯកឧត្តមបណ្ឌិតសភាចារ្យ **ជុំ ទិដ្ឋិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ទំព័រទី ៤២**
មតិរបស់ដៃគូអភិវឌ្ឍន៍ថ្លែងក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមបច្ចេកទេសដៃគូអភិវឌ្ឍន៍ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ




## ផ្នែកទី ១

# ព្រឹត្តិការណ៍

# កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*នាថ្ងៃអង្គារ ១៣ រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានរៀបចំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។*

កិច្ចប្រជុំនេះត្រូវបានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអង្គភាពក្រោមឱវាទ កសហវ.។ កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងតាមរយៈប្រព័ន្ធវីឌីអូ ដោយប្រើប្រាស់ប្រព័ន្ធ Intranet របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានរបៀបវារៈចំនួន ២÷ ①.ការត្រួតពិនិត្យសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដំណាក់កាលទី៣ និង ②.ការរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃការអនុវត្ត CAP3 និងការត្រៀមរៀបចំក្របខណ្ឌ CAP4។


កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាម Video Conference នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០

ឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការ **អ.គ.ហ.** បានរាយការណ៍ជូនអង្គប្រជុំអំពីលក្ខណៈពិសេស នៃរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ ដែលមានលក្ខណៈខុសប្លែកពីរបាយការណ៍ប្រចាំឆ្នាំមុនៗ ដោយ **អ.គ.ហ.** បានរៀបចំជាទស្សនាទានប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ដែលទទួលបានយោបល់បន្ថែមពីបណ្តាដៃគូអភិវឌ្ឍន៍ មានជាអាទិ៍÷ សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, អង្គការយូនីសេហ្វ និងមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ទស្សនាទាន ត្រូវបានរៀបចំឡើង ក្នុងគោលបំណងបង្កើនការចូលរួមពីគ្រប់ភាគីដែលមានការពាក់ព័ន្ធ រួមមានអង្គភាពក្រោមឱវាទ កសហវ. ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍។ ដៃគូអភិវឌ្ឍន៍បានចូលរួមរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធ FMIS និងសិទ្ធិភាពនៃផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី។ ទន្ទឹមនឹងការរៀបចំបូកសរុបរបាយការណ៍ខាងលើនេះ, **អ.គ.ហ.** បាននិងកំពុងធ្វើការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ (CAP3) និងត្រៀមរៀបចំក្របខណ្ឌ CAP4។

### ក.ការត្រួតពិនិត្យសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្ត PFMRP ដំណាក់កាលទី៣

**ភាពជឿទុកចិត្តនៃថវិកា** នៅតែអាចរក្សាបានជាសារវន្ត ដោយសារការអនុវត្តផែនការប្រមូលចំណូល និងចំណាយថវិកាជាតិសម្រេចបានល្អប្រសើរ ធៀបនឹងច្បាប់ថវិកា។ ប្រព័ន្ធគណនេយ្យភាពហិរញ្ញវត្ថុត្រូវបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជំហានទី១ និងជំហានទី២ ។ ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា ដើម្បីឱ្យក្លាយជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ។ សម្រាប់ការត្រៀមខ្លួនក្នុងជំហានបន្ទាប់ ឬគណនេយ្យភាពសមិទ្ធកម្ម, កសហវ. បាននិងកំពុងរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី, និងកែសម្រួលបទបញ្ញត្តិគតិយុត្តពាក់ព័ន្ធ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ ២០១៩-២០២៥, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ ២០១៩-២០២៣ ហើយយុទ្ធសាស្ត្រនីមួយៗមានផែនការសកម្មភាពលម្អិតច្បាស់លាស់ ដើម្បីឱ្យការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ, ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ជាយន្តការសម្រាប់ការគាំទ្រ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយជោគជ័យ និងចីរភាព, កសហវ. បានបណ្តុះបណ្តាលមន្ត្រីរាជការ នៃ កសហវ. និងក្រសួង-ស្ថាប័នចំនួន ១០៥៩ រូប លើជំនាញសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយកំពុងរៀបចំការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ និងរៀបចំផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាព ក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ៤ ។

### ខ.ការរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃការអនុវត្ត CAP3 និងការត្រៀមរៀបចំក្របខណ្ឌ CAP4

#### ❖ការរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃការអនុវត្ត CAP3

*របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣ មានលក្ខណៈខុសប្លែកពីរបាយការណ៍ប្រចាំឆ្នាំមុនៗដោយ **អ.គ.ហ.** បានរៀបចំជាទស្សនាទានប្រកបដោយភាពគ្រប់ជ្រុងជ្រោយដែលទទួលបានយោបល់បន្ថែមពីបណ្តាដៃគូអភិវឌ្ឍន៍*

ជាវិធីសាស្ត្រក្នុងការរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃ CAP3, **អ.គ.ហ.** ប្រើប្រាស់របាយការណ៍ត្រួតពិនិត្យ CAP3 របស់ជំនាញការដែលគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និងធ្វើការត្រួតពិនិត្យបន្ថែមនូវរបាយការណ៍វឌ្ឍនភាព នៃ PFMRP ទាំងប្រចាំត្រីមាស និងប្រចាំឆ្នាំ ។ ជាមួយគ្នានេះ អ.គ.ហ. ធ្វើការវិភាគអំពីវឌ្ឍនភាពសម្រេចបាន បញ្ហាប្រឈម វិធានការបន្ទាប់ដើម្បីត្រៀមបន្តទៅដំណាក់កាលទី ៤ ។ លទ្ធផល នៃការវាយតម្លៃបឋមបង្ហាញដូចខាងក្រោម÷

**ផ្នែកទី១ "ភាពជឿទុកចិត្ត នៃថវិកា"÷** ការពង្រឹង និងការគ្រប់គ្រងចំណូលមានស្ថានភាពល្អប្រសើរ និងបង្កើតឱ្យមានអតិរេកចរន្ត។ ការអនុវត្តចំណាយ ត្រូវបាន


កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាម Video Conference នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ នៅបន្ទប់ប្រជុំជាន់ផ្ទាល់ដី អគារ "ក"



កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាម Video Conference នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០

បន្តកែលម្អ និងស្ថិតក្នុងទិសដៅដែលបានកំណត់ ។ រីឯបំណុលសាធារណៈ ស្ថិតក្នុងស្ថានភាពអាចគ្រប់គ្រងបាន។ ប៉ុន្តែ មូលដ្ឋាន នៃប្រភពចំណូល នៅជាកត្តាបារម្ភសម្រាប់រក្សាចីរភាពកំណើនសេដ្ឋកិច្ច រីឯការអនុវត្តធៀបនឹងផែនការ នៅមិនទាន់ត្រូវបានវាយតម្លៃអំពីប្រសិទ្ធភាពទាំងក្របខណ្ឌនៃការព្យាករ និងសក្តានុពល ឬលទ្ធភាពនៃការកៀរគរចំណូល ។

**ផ្នែកទី២ “បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ”** ÷ លទ្ធផលជារួម បង្ហាញថាមានភាពល្អប្រសើរលើការងារដាក់ឱ្យដំណើរការប្រព័ន្ធ FMIS និងស្តង់ដារគណនេយ្យសាធារណៈ ដែលត្រូវបានកំណត់ជាផែនទីចង្អុលបង្ហាញផ្លូវ (Roadmap) ច្បាស់លាស់។

**ផ្នែកទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”** ÷ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន គឺជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលគុណភាពនឹងត្រូវធ្វើការកែលម្អជាបន្តបន្ទាប់ក្នុងជំហានទៅមុខ ។ រីឯក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម និងក្របខណ្ឌថវិការយៈពេលមធ្យម ត្បិតមានបញ្ហាប្រឈមក្នុងការដាក់ឱ្យអនុវត្ត ប៉ុន្តែមានក្របខណ្ឌទស្សនាទានច្បាស់លាស់។

**ផ្នែកទី៤ “ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់”** ÷ វឌ្ឍនភាពជារួមសម្រាប់ផ្នែកទី៤ បានបង្ហាញនូវភាពមិនទាន់ច្បាស់លាស់នៅរយៈពេល២ ឆ្នាំដំបូង ប៉ុន្តែ វឌ្ឍនភាពបានបង្ហាញយ៉ាងច្បាស់បន្ទាប់ពីយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ត្រូវបានរៀបចំ និងបានជ្រើសរើសយកប្រព័ន្ធ “**ថវិកាព័ត៌មានសមិទ្ធកម្ម**” ឬ “**ថវិកាសមិទ្ធកម្ម**” ជាទិសដៅជាក់លាក់នៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ។

**ផ្នែកទី៥ “ការគាំទ្រដល់ការអនុវត្តការកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព”** ÷ ការត្រួតពិនិត្យលើវឌ្ឍនភាពនៃផ្នែកទី៥ ផ្តោតលើវឌ្ឍនភាពនៃធាតុជាមូលដ្ឋានសម្រាប់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ៣ មាន÷ (១) ការគ្រប់គ្រងយន្តការការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) យន្តការលើកទឹកចិត្ត និង ប្រភពហិរញ្ញវត្ថុ, និង (៣) យន្តការអន្តរការដ្ឋានកែទម្រង់។ ជារួមការវាយតម្លៃបឋមបង្ហាញថា ការគ្រោងទុកក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី ៣ សម្រេចបានជាមូលដ្ឋាន និងមានទិសដៅច្បាស់លាស់សម្រាប់ឈានទៅដំណាក់កាលបន្ទាប់ ។

### ❖ ការត្រៀមរៀបចំក្របខណ្ឌ CAP4

ចំណុចដែលគួរពិចារណាក្នុងការត្រៀមរៀបចំក្របខណ្ឌ CAP4 រួមមាន (១) ការពន្យារពេលក្នុងការអនុវត្ត CAP4 (២០២១-២០២៥) តាមរយៈការពន្យារពេលអនុវត្ត CAP3 ១ ឬ ២ ឆ្នាំ ជាពិសេសក្នុងស្ថានភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ច (វិបត្តិកូវីដ-១៩), (២) ការពិនិត្យលើការអនុវត្តអភិក្រមជាខឿន (Platform), ការបង្កើតគោលបំណងឬចង្កោមសកម្មភាពថ្មី/ ដាច់ដោយឡែកសម្រាប់យុទ្ធសាស្ត្រថ្មីៗ ក្រោម PFMRP (៣) ការរៀបចំតារាងម៉ាទ្រីសតាមគោលបំណងផ្សារភ្ជាប់តាមខឿន (Platform) នីមួយៗ, (៤) ការគិតគូរអំពីទម្រង់របាយការណ៍ PFMRP សម្រាប់ដំណាក់កាលទី៤, និងការពិចារណាលើការបែងចែក CAP4 ជា ២ ដោយ GDAP4 សម្រាប់អគ្គនាយកដ្ឋាន និងMAP4 សម្រាប់ក្រសួង-ស្ថាប័ន។

មានប្រសាសន៍ក្នុងមតិបូកសរុប, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ណែនាំគ្រប់អង្គភាព ក្រោមឱវាទ កសហវ. បន្តជំរុញការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ និងការងារប្រទាក់ក្រឡាគ្នារវាងការដ្ឋានកែទម្រង់បីបូកមួយ (ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, វិមជ្ឈការនិងវិសហមជ្ឈការ, រដ្ឋបាលសាធារណៈ និងច្បាប់និងប្រព័ន្ធយុត្តិធម៌។ ជាចុងក្រោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ជូនពរគ្រប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។■

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*



# កិច្ចប្រជុំអនុម័តផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រចំនួន ៣ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

*គិតត្រឹមឆ្នាំ២០២០, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានអាយុកាលជាង ១៥ ឆ្នាំ និងបានបញ្ចប់ ២ ដំណាក់កាល ហើយកំពុងស្ថិតនៅក្នុងដំណាក់កាលទី៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” និងត្រូវឈានចូលដំណាក់កាលទី៤ “គណនេយ្យភាពសមិទ្ធកម្ម” នៅឆ្នាំ២០២១ ខាងមុខ។ ក្នុងដំណាក់កាលទី៣ នេះ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានលេចរូបរាងឡើងក្នុងអំឡុងត្រីមាសទី ១ ឆ្នាំ២០១៨ ដើម្បីជាប្រទីបបំភ្លឺផ្លូវឆ្ពោះទៅប្រព័ន្ធថវិកាក្នុងម៉ូដែលជាប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅថាថវិកាសមិទ្ធកម្ម។ រីឯផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រខាងលើ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅឆមាសទី១ ឆ្នាំ២០១៩ ។*

ក្រោមផ៉ែត្រយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រចំនួន ៤[1] បន្ថែម ត្រូវបានអនុម័តជាបន្តបន្ទាប់ ដោយប្រមុខរាជរដ្ឋាភិបាល និងផែនការសកម្មភាពគាំទ្រ ត្រូវបានអនុម័តដោយប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

នាថ្ងៃចន្ទ ០៨ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក, នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដឹកនាំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងអនុម័តផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រចំនួន ៣[2] រួមមាន (១) យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, (២) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, (៣) យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ២០២០-២០២៥។ កិច្ចប្រជុំនេះ មានការចូលរួមពីឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងជាសមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិង



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកិច្ចប្រជុំអនុម័តផែនការសម្រាប់អនុវត្តយុទ្ធសាស្ត្រចំនួន ៣ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

[1] (១) យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣, (២) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, (៣) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩-២០២៥, និង (៤) យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥

[2] ផែន ការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានអនុម័តនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២០

ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ហិរញ្ញវត្ថុ។

ផ្អែកតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពិភាក្សាលើការរៀបចំផែនការសកម្មភាពលម្អិត កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩, ផែនការសកម្មភាពលម្អិត និងផែនការយុទ្ធសាស្ត្រ ដូចបានរៀបរាប់ពីខាងដើម ត្រូវបានបន្តពិភាក្សាក្នុងកម្រិតអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ដើម្បីធានាបាននូវសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយ មុននឹងដាក់ឆ្លងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ តាមរយៈការរាយការណ៍ដោយក្រុមការងារ ក្នុងកិច្ចប្រជុំគណៈកម្មការ, ផែនការសកម្មភាពនីមួយៗ មានខ្លឹមសារដោយសង្ខេបខ្លីដូចខាងក្រោម÷

❖ **ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ត្រូវបានរៀបចំឡើងដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងជំរុញឱ្យសម្រេចបាននូវគោលបំណងនៃការធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធដែលសំដៅធានាចីរភាពកំណើនចំណូល និងពង្រឹងគុណភាពសេវា។ សកម្មភាពសរុបសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ មានចំនួន ៣៧៥ ដែលមានការបញ្ជាក់យ៉ាងច្បាស់លាស់អំពីអង្គភាពទទួលខុសត្រូវ និងក្របខណ្ឌពេលវេលា ទៅតាមត្រីមាសនីមួយៗនៃឆ្នាំ ដើម្បីធានាសម្រេចឱ្យបាននូវវិធានការទាំង ១២៥ និងសូចនាករសមិទ្ធកម្មគន្លឹះ ទាំង ១៨៥។

❖ **ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥** ត្រូវបានរៀបចំឡើងដោយផ្អែកទាំងស្រុងលើផែនទីចង្អុលផ្លូវ ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ ដោយបំបែកជាសកម្មភាពលម្អិត និងបានកំណត់យ៉ាងច្បាស់អំពីក្របខណ្ឌពេលវេលាទៅតាមត្រីមាសនីមួយៗ នៃឆ្នាំព្រមទាំងបានកំណត់ច្បាស់លាស់អំពីអង្គភាព ឬស្ថាប័នទទួលខុសត្រូវលើការអនុវត្តសកម្មភាពកែទម្រង់នីមួយៗ ។ សកម្មភាពដែលជាសមាសធាតុគន្លឹះៗ មានចំនួន ១៩ និងត្រូវបានចែកចេញជាសកម្មភាពលម្អិតចំនួន ៩៣ សម្រាប់ដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២៥ ។

❖ **ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥** ត្រូវបាន រៀបចំឡើងក្នុងគោលដៅឆ្ពោះទៅ

*បន្ទាប់ពីពិនិត្យលើសេចក្តីព្រាងចុងក្រោយផែនការសកម្មភាពនីមួយៗគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន អនុម័តផែនការសកម្មភាព ទាំង ៤ និង ស្នើអង្គភាពដែលមានការពាក់ព័ន្ធទាំងឡាយ អនុវត្តនូវផែនការសកម្មភាពទាំងនេះ ប្រកបដោយភាពម៉ឺងម៉ាត់និងមានប្រសិទ្ធភាពខ្ពស់ ។*

ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រថវិកា សម្រាប់ឈានទៅអនុវត្តប្រព័ន្ធ «ថវិកាព័ត៌មានសមិទ្ធកម្ម» ក្រោយឆ្នាំ២០២៥ ស្របតាមបង្គោលចរនៃផែនទីចង្អុលផ្លូវ និងត្រូវបានរៀបចំជាឧបសម្ព័ន្ធតាមវដ្តថវិកា ដោយមានសកម្មភាពសរុបចំនួន ១៤១ ចែកចេញជា ០៦ ផ្នែក, ១៣ គោលបំណង និង០២ ដំណាក់កាលដើម្បីសម្រេចនូវបង្គោលចរទាំង ៣៧។



កិច្ចប្រជុំអនុម័តផែនការសកម្មភាពចំនួន ៣ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

❖ **ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារ តាម FMIS ២០២០-២០២៥** ត្រូវបានរៀបចំឡើងក្នុងគោលបំណងតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកំពុងអនុវត្តទាំងក្នុង និងក្រៅប្រព័ន្ធបច្ចុប្បន្ន ឱ្យទៅជានីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ទាំងស្រុង ដើម្បីពង្រឹង និងបង្កើន តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផែនការយុទ្ធសាស្ត្រនេះ មានវិសាលភាពគ្របដណ្តប់នៅគ្រប់ការដ្ឋានរបស់ប្រព័ន្ធ FMIS លើនីតិវិធីអនុវត្តការងារទាំងឡាយ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធ FMIS និងដោយផ្អែកលើអភិក្រមជាជំហានៗ នៃប្រភេទនីតិវិធីអនុវត្តការងារ «ហានិភ័យ ឬវេទយិតភាពពីទាបទៅខ្ពស់»។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានឯកភាពលើសំណើរបស់ក្រុមការងារ FMIS ក្នុងការដាក់ឱ្យអនុវត្តសាកល្បងនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវនីតិវិធីតម្រង់ទិសថ្មីលើការទូទាត់បៀវត្សនៅក្នុងខែមេសា និងមុខសញ្ញាចំណាយទូទាត់ត្រង់ផ្សេងទៀតនៅកំឡុងខែមិថុនា ឆ្នាំ២០២០។

បន្ទាប់ពីពិនិត្យលើសេចក្តីព្រាងចុងក្រោយផែនការសកម្មភាពនីមួយៗ គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអនុម័តផែនការសកម្មភាពទាំង ៤ និងស្នើអង្គភាពដែលមានការពាក់ព័ន្ធអនុវត្តនូវផែនការសកម្មភាពទាំងនេះ ប្រកបដោយភាពម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ ។

ជាចុងបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងសមាជិក ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានខិតខំរៀបចំផែនការសកម្មភាពដ៏មានសារៈសំខាន់សម្រាប់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជូនពរគ្រប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕■

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*



កិច្ចប្រជុំអនុម័តផែនការសកម្មភាពចំនួន ៣ និងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

# ពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន ១៧ និងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣"

*នៅថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំពិធី "ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាផ្លូវការ នៅក្រសួង-ស្ថាប័នចំនួន ១៧ និងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣"។*

ពិធីនេះត្រូវបានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័ន និងតំណាងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

គោលបំណងនៃ ពិធីនេះ គឺដើម្បីដាក់ឱ្យក្រសួង-ស្ថាប័នទាំង ១៧ និង អង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំង ១៣ ប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការក្នុងការធ្វើប្រតិបត្តិការអនុវត្តថវិកា និងហិរញ្ញវត្ថុរបស់ខ្លួនបាន ចាប់ពីឆ្នាំ ២០២០ នេះតទៅ ដោយប្រើប្រាស់មុខងារស្នូលចំនួន ៤ របស់ប្រព័ន្ធ FMIS រួមមាន÷

❶. មុខងារវិភាជន៍ថវិកា
❷. មុខងារទិញ និងធានាចំណាយ
❸. មុខងារគណនីត្រូវសង និងចំណាយថវិកា
❹. មុខងារគណនីត្រូវទារ និងចំណូលថវិកា

ក្រសួង-ស្ថាប័នទាំង ១៧ រួមមាន÷ (១). ក្រសួងព្រះបរមរាជវាំង, (២). អគ្គលេខាធិការដ្ឋានរដ្ឋសភា, (៣). អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, (៤). អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ,(៥). ទីស្តីការគណៈរដ្ឋមន្ត្រី, (៦). ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, (៧). ក្រសួងការពារជាតិ, (៨). ក្រសួងមហាផ្ទៃ (ទាំងផ្នែកសន្តិសុខសាធារណៈ និងផ្នែករដ្ឋបាលទូទៅ),(៩). ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, (១០). ក្រសួងរ៉ែ និងថាមពល, (១១). ក្រសួងផែនការ, (១២). ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, (១៣). ក្រសួងធម្មការ និងសាសនា, (១៤). ក្រសួងយុត្តិធម៌ (រួមទាំង ស្ថាប័នតុលាការ),(១៥). គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, (១៦). អាជ្ញាធរសវនកម្មជាតិ និង (១៧). អង្គភាពប្រឆាំងអំពើពុករលួយ ។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** បានថ្លែងថាការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដល់ក្រសួង-ស្ថាប័នទាំង ១៧ គឺជាប្រវត្តិសាស្ត្រថ្មីមួយទៀត នៅក្នុងដំណើរការអនុវត្តគម្រោង FMIS ដែលក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្នាក់កណ្តាលទាំងអស់ បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយប្រកបដោយភាពជឿទុកចិត្ត និង មានគុណភាពខ្ពស់ ក្នុងការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិកាជាតិ។ ឯកឧត្តមបណ្ឌិតសភាចារ្យ បានបន្តថា ប្រព័ន្ធនេះ អាចជួយដល់ថ្នាក់ដឹកនាំ មានមូលដ្ឋានរឹងមាំ និងច្បាស់លាស់ ក្នុងការសម្រេចចិត្តទាន់ពេលវេលា ព្រមទាំងឈានទៅក្តាប់យកកាលានុវត្តភាពប្រកបដោយជវភាពពីបដិវត្តន៍ឧស្សាហកម្មទី ៤ និងសក្តានុពលនៃសេដ្ឋកិច្ចឌីជីថល ដែលនេះ "ជាជំហានមួយថ្មីទៀត រួមចំណែកដល់ការសម្រេចបានគោលដៅការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្ម ៤.០ ដែលកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល"។

ឯកឧត្តមបណ្ឌិតសភាចារ្យ ក៏បានគូសបញ្ជាក់ផងដែរអំពីតួនាទីសំខាន់របស់ប្រព័ន្ធ FMIS ក្នុងការជួយពង្រឹងប្រសិទ្ធភាព, គណនេយ្យភាព, តម្លាភាព និងគាំទ្រដល់ការ




ពិធី ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន ១៧ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

គ្រប់គ្រង និងតាមដានការអនុវត្ត ថវិកា និងហិរញ្ញវត្ថុ ស្របពេលដែលគ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធី និងការបង្កើតអង្គភាពថវិកាជាពិសេសគាំទ្រដល់ដំណើរឈានឆ្ពោះទៅដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺគណនេយ្យភាពសមិទ្ធកម្មនៅឆ្នាំ២០២១ ខាងមុខនេះ។ ម្យ៉ាងទៀតប្រព័ន្ធ FMIS ចូលរួមគាំទ្រដល់ការទូទាត់តាមអេឡិកត្រូនិក, ការធ្វើសន្ទានកម្មផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធខាងក្រៅដោយស្វ័យប្រវត្តិ, ការលើកកម្ពស់គុណភាពនៃការផលិត និងទាញយករបាយការណ៍តាមតម្រូវការចាំបាច់ផ្ទាល់របស់ក្រសួងសាមីនីមួយៗ នឹងធ្វើ ឱ្យការប្រើប្រាស់ប្រព័ន្ធ FMIS គឺជាប្រព័ន្ធតែមួយគត់ ដែលគាំទ្រដោយផ្ទាល់ទៅលើការអនុវត្តកម្មវិធីគន្លឹះនានា នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយនឹងរួមចំណែកធ្វើឱ្យប្រទេសកម្ពុជាប្រែក្លាយទៅជារាជរដ្ឋាភិបាលឌីជីថល នៅក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ក្នុងបរិការណ៍ នៃបដិវត្តន៍ឧស្សាហកម្មទី ៤ ។

ឯកឧត្តមបណ្ឌិតសភាចារ្យ បានផ្តល់ការលើកទឹកចិត្ត និងគូសបញ្ជាក់អំពីចំណុចសំខាន់ៗមួយចំនួន ដល់អ្នកចូលរួម មកពីក្រសួង-ស្ថាប័ន ក្នុងការបន្តកិច្ចសហការអនុវត្តគម្រោង FMIS ក្នុងនោះ រួមមាន÷

១. អគ្គនាយកដ្ឋានគន្លឹះៗនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តចូលរួមប្រកបដោយបុរេសកម្មក្នុងការជួយតម្រង់ទិស និងគាំទ្រដល់អ្នកប្រើប្រាស់ថ្មីៗ ក្នុងប្រព័ន្ធ FMIS, ជួយផ្សព្វផ្សាយ និងផ្តល់ការណែនាំឱ្យបានទូលំទូលាយ អំពីការផ្សារភ្ជាប់រវាងការអនុវត្តថវិកា និងការប្រើប្រាស់ប្រព័ន្ធព្រមទាំងនីតិវិធីអនុវត្ត ថវិកា និង ការពង្រឹងគណនេយ្យភាពនៃប្រតិបត្តិការហិរញ្ញវត្ថុនៅក្នុងប្រព័ន្ធ FMIS។

២. ក្រសួង-ស្ថាប័នដែលប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវបន្តបង្កើនសមត្ថភាពជំនាញ, ទាំងជំនាញហិរញ្ញវត្ថុសាធារណៈ និងជំនាញ

> *ការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដល់ក្រសួង-ស្ថាប័នទាំង ១៧ គឺជាប្រវត្តិសាស្ត្រថ្មីមួយទៀត នៅក្នុងដំណើរការអនុវត្តគម្រោង FMIS ដែលក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្នាក់កណ្តាលទាំងអស់ បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយប្រកបដោយភាពជឿទុកចិត្ត និងមានគុណភាពខ្ពស់ ក្នុងការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិកាជាតិ។*

ក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានភាពជាម្ចាស់ ក្នុងការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុរបស់ខ្លួន តាមរយៈការប្រើប្រាស់ប្រព័ន្ធ FMIS ។

៣. ក្រសួង-ស្ថាប័ន និង អង្គភាពទាំងអស់ ដែលប្រើប្រាស់ប្រព័ន្ធ FMIS ត្រូវធ្វើការត្រួតពិនិត្យនូវមុខងារ និងតួនាទីរបស់មន្ត្រីម្នាក់ៗ, រចនាសម្ព័ន្ធការងារផ្ទៃក្នុង និងកំណត់នូវកម្រិតហានិភ័យ នៃប្រភេទប្រតិបត្តិការអនុវត្តថវិកា និងហិរញ្ញវត្ថុជាបណ្តើរៗ ដើម្បីត្រៀមខ្លួនសហការជាមួយក្រុមការងារគ្រប់គ្រងគម្រោង FMIS ក្នុងការរៀបចំនីតិវិធីតម្រង់ទិសថ្មី ស្របតាមផែនការតម្រង់ទិសនីតិវិធីអនុវត្តការងារ (Business Processes Streamlining)។

៤. អ្នកប្រើប្រាស់ប្រព័ន្ធ FMIS ទាំងអស់ ត្រូវចូលរួមពង្រឹងគណនេយ្យភាព នៃការប្រើប្រាស់ប្រព័ន្ធ FMIS ដោយធ្វើការពិនិត្យឱ្យបានម៉ត់ចត់លើទិន្នន័យ ដែលបានកត់ត្រាចូលក្នុងប្រព័ន្ធ FMIS និងប្រើប្រាស់ព័ត៌មានពីប្រព័ន្ធ FMIS ជាគោល សម្រាប់ការគ្រប់គ្រង និងអនុវត្តថវិកាតាមរយៈការវិភាគ, តាមដាន, ត្រួតពិនិត្យ និងការរៀបចំរបាយការណ៍នានាស្តីអំពីឥណទានថវិកា និងការអនុវត្តថវិកា ៕■

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*



ពិធី ប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន ១៧ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

# ផ្នែកទី ២

# អត្ថបទ


ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTERE DE L'ECONOMIE ET DES FINANCES
MINISTRY OF ECONOMY AND FINANCE

# វឌ្ឍនភាពប្រចាំឆ្នាំ ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣

*អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "វិធាន និង នីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ", អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានរៀបចំបូកសរុបវឌ្ឍនភាពឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ។*

ក្នុងដំណាក់កាលនេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) បានកំណត់អាទិភាពចំនួន ៣ រួមមាន (១). ពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូល និងចំណាយ, (២). ពង្រឹង និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង (៣). ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី។

ក្នុងកិច្ចដំណើរការបូកសរុបវឌ្ឍនភាពប្រចាំឆ្នាំ២០១៩ ដោយមានការអនុញ្ញាតពី **គ.ហ.ស., អ.គ.ហ.** បានជ្រើសរើសវិធីសាស្រ្ត ចំនួន ៣ រួមមាន (១) ការត្រួតពិនិត្យតាមដាន និងបូកសរុបវឌ្ឍនភាពស្របតាមក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៣ ២០១៩-២០២០, (២) ការចុះជួបពិភាក្សាជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[១] ស្តីពីការរៀបចំ និងអនុវត្តផែនការសកម្មភាព (MAP/GDAP) ឆ្នាំ២០១៩ និង (៣) ការចូលរួមពីដៃគូអភិវឌ្ឍន៍ (សហភាពអឺរ៉ុប, ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក, អង្គការយូនីសេហ្វ និងមូលនិធិរូបិយវត្ថុអន្តរជាតិ) លើការគ្រប់គ្រងការផ្លាស់ប្តូរនិងការតម្រង់ទិសនីតិវិធីអនុវត្តការងារ និងការត្រួតពិនិត្យលើសមានគតិភាពរវាងផែនការយុទ្ធសាស្រ្តថវិកា និងថវិកាកម្មវិធី ។ ក្នុងស្មារតីនេះ វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ ឆ្លុះបញ្ចាំងដោយសង្ខេប ដូចខាងក្រោម÷




ផ្សាក្រាម១÷ ការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះទាំង ៦ | ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយ

*[១] ចុះប្រមូលព័ត៌មានបន្ថែមនៅអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន ចាប់ពីថ្ងៃទី១៣-២៧ ខែកុម្ភៈ ឆ្នាំ២០២០ ក្នុងនោះអង្គភាពក្រោមឱវាទ កសហវ. រួមមាន អគ្គនាយកដ្ឋានគោលនយោបាយ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ក្រសួង-ស្ថាប័ន រួមមាន ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងរ៉ែនិងថាមពល, អាជ្ញាធរសវនកម្មជាតិ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងមុខងារសាធារណៈ និងក្រសួងផែនការ។ ទន្ទឹមនេះ រដ្ឋបាលរាជធានី-ខេត្ត រួមមាន រដ្ឋបាលរាជធានីភ្នំពេញ, រដ្ឋបាលខេត្តកណ្តាល និងរដ្ឋបាលខេត្តព្រៃវែង ត្រូវបានជ្រើសរើសសម្រាប់ការសិក្សាផងដែរ។*








ផ្សាក្រាម២÷ ការអនុវត្តផែនការប្រមូលចំណូល | ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានគោលនយោបាយ

❖ ការអនុវត្តយុទ្ធសាស្រ្តកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ប្រកបដោយភាពម៉ឺងម៉ាត់ និងមុតស្រួច បានជំរុញកំណើនចំណូលចរន្តកើនឡើងជាលំដាប់។ ជាមធ្យមចាប់ពីឆ្នាំ២០១៤-២០១៨ ចំណូលចរន្តបានកើនឡើងប្រមាណ ១,៤៣ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុង មួយឆ្នាំ; រីឯឆ្នាំ២០១៩ មានកំណើន ៣,១៨ [២] ពិន្ទុភាគរយ នៃ ផ.ស.ស.។ សមិទ្ធផលនេះ ទទួលបានមូលវិចារណ៍ល្អគួរជាទីមោទនៈ, ទាំងពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងពីសំណាក់ដៃគូអភិវឌ្ឍន៍និងស្ថាប័នអន្តរជាតិ ព្រមទាំងបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចបង្វែរថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាពក៏ដូចជាអាចបង្កើនយ៉ាងច្រើននូវធនធានវិនិយោគសាធារណៈក្នុងស្រុក ពិសេសលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែល ជាប្រការជួយលើកស្ទួយមួយកម្រិត ដល់ឯករាជ្យភាពផ្នែកថវិការបស់កម្ពុជា ។






*ប្រភព÷អគ្គនាយកដ្ឋានរតនាគារជាតិ*

❖ ការអនុវត្តថវិកាសម្រេចបាន ៩៩.០៥% នៃច្បាប់ថវិកា (ស្ថិតក្នុងរង្វង់ +/-៥%) រីឯការចំណាយប្រចាំត្រីមាស មានភាពយឺតយ៉ាវ ហើយគំហុកក្នុងត្រីមាសទី៤ ដែលបណ្តាលមកពីសមត្ថភាពអង្គភាពថវិកា, ការរៀបចំផែនការថវិកាមិនទាន់ច្បាស់លាស់, ការធ្វើនិយ័តឆ្លងកម្មវិធីអនុកម្មវិធី និងចង្កោមសកម្មភាព, ការទូទាត់ថវិកាបុរេប្រទាននិងការទូទាត់ប្រាក់រង្វាន់មានភាពយឺតយ៉ាងទន្ទឹមនឹងការចាប់ផ្តើមអនុវត្តគម្រោងវិនិយោគដោយថវិកាជាតិ មានភាពយឺតយ៉ាវផងដែរ ។

*[២] លើសជាង ១០ ដង នៃគោលដៅដែលបានដាក់ចេញក្នុងយុទ្ធសាស្រ្តកៀរគរចំណូល ២០១៩-២០២៣ ខណៈគោលដៅត្រឹម ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស.*







*ប្រភព៖ អគ្គនាយកដ្ឋានរតនាគារជាតិ*

*ការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ប្រកបដោយភាពម៉ឺងម៉ាត់ និងមុតស្រួច បានជំរុញកំណើនចំណូលចរន្តកើនឡើងជាលំដាប់ ។*

❖ គម្រោង FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជំហានទី១ នៅឆ្នាំ២០១៤ និងជំហានទី២ នៅឆ្នាំ២០១៧។ មុខងារស្នូល និងចំណាត់ថ្នាក់ថវិកាត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ។ ប្រព័ន្ធ FMIS ត្រូវបានពង្រីកការអនុវត្តដល់ក្រសួង-ស្ថាប័នចំនួន ៣៧ ក្នុងនោះ ឆ្នាំ២០១៨ មាន ១០ ក្រសួង-ស្ថាប័ន, ឆ្នាំ២០១៩ មាន ១០ ក្រសួង-ស្ថាប័ន, និងឆ្នាំ២០២០ មាន ១៧ ក្រសួង-ស្ថាប័នថ្មីបន្ថែម ។

❖ ប្រព័ន្ធ FMIS ត្រូវបានរៀបចំ អភិវឌ្ឍ និងដាក់ឱ្យដំណើរការរួចរាល់នូវមុខងារសន្ធានកម្មមួយចំនួន រួមមាន (១) សន្ធានកម្មរបាយការណ៍ធនាគារ (Bank Statement) ជាមួយធនាគារជាតិនៃកម្ពុជា, ធនាគារកាណាឌីយ៉ា, ធនាគារអេស៊ីលីដា, ធនាគារកម្ពុជាសាធារណៈ, ធនាគារវឌ្ឍនៈ និងធនាគារ ANZ Royal, (២) សន្ធានកម្មការទូទាត់តាមអេឡិចត្រូនិក (EFT) ជាមួយធនាគារជាតិនៃកម្ពុជា, (៣) សន្ធានកម្មចំណូលពន្ធគយ និងរដ្ឋាករជាមួយប្រព័ន្ធ ASYCUDA របស់អគ្គនាយកដ្ឋាន គយ និងរដ្ឋាករកម្ពុជា, (៤) សន្ធានកម្មចំណូលមូលធនជាមួយប្រព័ន្ធ DMFAS របស់អគ្គនាយកដ្ឋានសហប្រតិបត្តិការនិង គ្រប់គ្រងបំណុល និង (៥) សន្ធានកម្មចំណូលមិនមែនសារពើពន្ធជាមួយប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

❖ ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមបច្ចេកវិទ្យាព័ត៌មានត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងនៅក្រសួង-ស្ថាប័នចំនួន ១០ នៅដើមឆ្នាំ ២០២០ ក្នុងគោលបំណងត្រួតពិនិត្យ តាមដាន កត់ត្រា និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមក្រសួង-ស្ថាប័ន, អង្គភាពប្រើប្រាស់ និងអង្គភាពកាន់កាប់ទ្រព្យសម្បត្តិរដ្ឋឱ្យមានប្រសិទ្ធភាពខ្ពស់។

❖ ការអនុវត្តថវិកាកម្មវិធី ត្រូវបាន និងកំពុងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត ។ ជាវឌ្ឍនភាពក្រសួង-ស្ថាប័ន ចំនួន ១០ អនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០១៥, ក្រសួង-ស្ថាប័ន ចំនួន ១៥ ក្នុងឆ្នាំ២០១៦ និង ក្រសួង-ស្ថាប័ន ចំនួន ១១ ក្នុងឆ្នាំ២០១៧ និង ក្រសួង-ស្ថាប័ន ចំនួន ៣ ក្នុងឆ្នាំ២០១៨ សរុបចំនួន ៣៩ ។ ឯ រដ្ឋបាលរាជធានី-ខេត្ត ត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធី ចាប់ពីឆ្នាំ២០១៧-២០២១ ^(៣)។ មកដល់ពេលនេះ, អង្គភាពថវិកាចំនួន ៩១២ ក្នុងនោះអង្គភាព ថវិកាអាណាប័កផ្ទេរសិទ្ធិចំនួន ៦៦៤ និងមិនទាន់ផ្ទេរសិទ្ធិ ចំនួន ២៤៨ ។ សម្រាប់ថ្នាក់កណ្តាល មានចំនួន ៣០៨ ក្នុងនោះ អង្គភាព ថវិកាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៤០ និងមិនទាន់ផ្ទេរសិទ្ធិចំនួន ២៤៨ និង សម្រាប់ថ្នាក់មូលដ្ឋានមានចំនួន ៦០៤ ជាអាណាប័កផ្ទេរសិទ្ធិទាំងអស់ ។

❖ មូលនិធិនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានផ្តល់ជូនក្រុម

*តារាងផែនការអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលរាជធានី-ខេត្ត*

| ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| កំពង់ស្ពឺ | កំពង់ឆ្នាំង | កណ្តាល | កំពង់ចាម | រាជធានីភ្នំពេញ |
| កែប | ពោធិ៍សាត់ | បាត់ដំបង | កំពង់ធំ | |
| កោះកុង | តាកែវ | បន្ទាយមានជ័យ | ព្រះវិហារ | |
| ប៉ៃលិន | កំពត | ស្វាយរៀង | ឧត្តរមានជ័យ | |
| ក្រចេះ | ព្រៃវែង | ត្បូងឃ្មុំ | សៀមរាប | |
| ស្ទឹងត្រែង | រតនគិរី | មណ្ឌលគិរី | ព្រះសីហនុ | |



ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ការអនុវត្តថវិកាកម្មវិធី ត្រូវបាននិងកំពុងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត ។*

ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័នចំនួន ៣៤៦ រូប និងទឹកប្រាក់សរុបចំនួន ៥ ០១៦ លានរៀល ។ ទន្ទឹមនេះ **អ.គ.ហ.** បាន និងកំពុងរៀបចំមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគ្រប់ជ្រុងជ្រោយ ។

❖ បន្ទាប់ពីការដាក់ឱ្យអនុវត្ត "**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥**" និងផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះដែលជាស្នូល នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រចំនួន ៤បន្ថែម រួមមាន (១) "**យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣**", (២) "**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**", (៣) "**យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥**" និង (៤) "**យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ ២០១៩-២០២៥**" រីឯផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងបួនខាងលើ ត្រូវបានអនុម័តក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០២០ ។ ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ២០២០-២០២៥ ក៏ត្រូវបានអនុម័តក្នុងអំឡុងត្រីមាសទី ១ ឆ្នាំ២០២០ ផងដែរ ។

ផ្អែកលើវឌ្ឍនភាពគន្លឹះៗសម្រេចបានខាងលើ ចក្ខុវិស័យកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែមានភាពច្បាស់លាស់ និងប្រាកដនិយម ព្រមទាំងអាចសន្និដ្ឋានថា (១) ភាពជឿទុកចិត្តនៃថវិកានៅតែអាចរក្សាបានជាសារវន្ត ប៉ុន្តែត្រូវពង្រឹងបន្ថែមលើប្រសិទ្ធភាពចំណាយ និងការគ្រប់គ្រងចំណូល ជាពិសេសការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ, (២) ប្រព័ន្ធគណនេយ្យភាពបាននិងកំពុងកសាងតាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ជំហានទី១ និងទី២ ប៉ុន្តែត្រូវពង្រឹងបន្ថែមទៀតនូវគុណភាពនៃសមាសធាតុនីមួយៗ, (៣) ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំ និងកំណត់ការផ្លាស់ប្តូរប្រព័ន្ធថវិកាកម្ពុជា ព្រមទាំងបន្តពង្រឹងការរៀបចំ និងអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងក្របខណ្ឌថវិការយៈពេលមធ្យមដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ, (៤) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា និងយុទ្ធសាស្ត្រគាំទ្រប្រព័ន្ធថវិកា ជាសមាសធាតុសំខាន់ ដើម្បីកំណត់ទិសដៅ គណនេយ្យភាពសមិទ្ធកម្មដែលជាគោលដៅចុងក្រោយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង (៥) ប្រព័ន្ធលើកទឹកចិត្ត ត្រូវបាននិងក្លាយជាឧបករណ៍ ដើម្បីជំរុញការធ្វើស្ថាបន្នបនីយកម្មឱ្យស្របតាមការវិវឌ្ឍនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកសាងធនធានមនុស្សបាននិងកំពុងលើកកម្ពស់មន្ត្រីរាជការជាលំដាប់តាមរយៈការដាក់ ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាព ៕■



*រៀបចំដោយ៖ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*

# វិធានការចំពោះមុខប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ (Covid-19)

*បន្ទាប់ពីសេចក្តីរីករាយនឹងការប្រារព្ធពិធីបុណ្យឆ្លងឆ្នាំសកល ២០២០, ពិភពលោកទាំងមូល បានចាប់ផ្តើមផ្លាស់ប្តូរស្ថានភាពបន្តិចម្តងៗ ពីភាពអ៊ូអរ រហូតដល់ស្ងាត់ជ្រងំ។ ជំងឺរលាកសួតប្រភេទថ្មី ត្រូវបានគេដាក់ឈ្មោះថា Covid-19 គឺបានចាប់ផ្តើមទូទាំងសកលលោក ដែលបង្កឱ្យមនុស្សអាចបាត់បង់អាយុជីវិតក្នុងរយៈពេលដ៏ខ្លី ខណៈដែលថ្នាំព្យាបាល ឬវ៉ាក់សាំងការពារ នៅកំពុងស្ថិតក្នុងការស្រាវជ្រាវ និងសាកល្បងនៅឡើយ។*

Covid-19 មិនត្រឹមតែជាជំងឺឆ្លងដល់មនុស្សតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជាជំងឺរាតត្បាតដល់កំណើនសេដ្ឋកិច្ចទូទាំងសកលលោក។ រដ្ឋាភិបាលគ្រប់ប្រទេស បានរៀបចំប្រជុំ ពិភាក្សា និងសម្រេចដាក់ចេញនូវវិធានការបន្ទាន់ និងចាំបាច់នានា ដើម្បីធានាសុវត្ថិភាពប្រជាពលរដ្ឋទាំងអស់ និងធានាលំនឹងសេដ្ឋកិច្ច។

សម្រាប់កម្ពុជា, ខណៈដែលពិភពលោកកំពុងតែពើបប្រទះការរាតត្បាតយ៉ាងឆាប់រហ័ស បើទោះបីជាខ្លួនមិន ទាន់ជួបប្រទះនៅតួរលេខនៃកំណើនការឆ្លងក្នុងត្រីមាសទី១ ក៏ដោយ, រាជរដ្ឋាភិបាលកម្ពុជា ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាអគ្គមេបញ្ជាការតែមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដឹកនាំ និងចង្អុលគ្រប់ក្រសួងស្ថាប័ន និងវិស័យឯកជន ឱ្យបុរេសកម្មក្នុងការប្រុងប្រៀបប្រយុទ្ធប្រឆាំងនឹងជំងឺនេះ ដូចជា ក្រសួងអប់រំ យុវជន និងកីឡា ចេញសេចក្តីណែនាំ ក្នុងការផ្អាកបណ្តោះអាសន្នសម្រាប់គ្រឹះស្ថានអប់រំទាំងស្ថាប័នរដ្ឋ និងឯកជន ដោយគិតគូរតាមរបៀបថ្មី គឺការរៀនតាមប្រព័ន្ធអនឡាញ, សេចក្តីណែនាំរបស់ក្រសួងសុខាភិបាលក្នុងការធ្វើអនាម័យ និងការផ្អាកការជួបជុំ, និងសេចក្តីណែនាំរបស់ស្ថាប័នផ្សេងទៀតផងដែរ។

*សម្រាប់កម្ពុជា, ខណៈដែលពិភពលោកកំពុងតែពើបប្រទះការរាតត្បាតយ៉ាងឆាប់រហ័ស បើទោះបីជាខ្លួនមិនទាន់ជួបប្រទះនៅតួរលេខនៃកំណើនការឆ្លងក្នុងត្រីមាសទី១ក៏ដោយ, រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអគ្គមេបញ្ជាការតែមួយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានដឹកនាំនិងចង្អុលគ្រប់ក្រសួងស្ថាប័ន និងវិស័យឯកជន ឱ្យបុរេសកម្មក្នុងការប្រុងប្រៀបប្រយុទ្ធប្រឆាំងនឹងជំងឺនេះ*

ជាការពិត, វិបត្តិនៃជំងឺរាតត្បាត Covid-19 នេះក៏បានបង្កឱ្យមានផលប៉ះពាល់ដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផងដែរ ក្នុងនោះផែនការសកម្មភាពកែទម្រង់ដែលត្រូវបានគ្រោងសម្រាប់ការអនុវត្តក្នុងឆ្នាំ ២០២០ នេះ របស់គ្រប់ក្រសួងស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏នឹងត្រូវត្រួតពិនិត្យឡើងវិញ។ ដោយឡែកសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានកោះហៅប្រជុំបន្ទាន់ដើម្បីរៀបចំក្រុមការងារដោះស្រាយ និងទប់ស្កាត់ និងវិធានការបន្ទាន់នានា ដើម្បីចូលរួមរក្សានូវលំនឹងសេដ្ឋកិច្ច, រក្សានូវសកម្មភាពអភិវឌ្ឍន៍, និងការធានានូវការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការជាប្រចាំ។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញនូវសេចក្តីសម្រេចក្នុងការបង្កើតក្រុមការងារបច្ចេកទេសដើម្បីដោះស្រាយ និងទប់ស្កាត់ រួមមានជាអាទិ៍÷ ❶.សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះចំពោះកិច្ចសិក្សារៀបចំដាក់ចេញនូវកញ្ចប់វិធានការខាងរូបិយវត្ថុ និងធនាគារ ដើម្បីគ្រប់គ្រង និងដោះស្រាយផលប៉ះពាល់ពីការរីករាលដាល នៃជំងឺកូវីដ-១៩ និងការព្យួរប្រព័ន្ធអនុគ្រោះពន្ធលើមុខទំនិញមួយចំនួនក្នុងក្របខណ្ឌ "ទំនិញគ្រប់យ៉ាងលើកលែងតែសព្វាវុធ (EBA)", ❷.សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចរៀបចំគោលនយោបាយថវិកា ហិរញ្ញប្បទាន និងជំនួយសង្គមដើម្បីគ្រប់គ្រងការប្រយុទ្ធនឹងជំងឺកូវីដ-១៩, ❸.សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចរៀបចំ និងគ្រប់គ្រងយន្តការជំនួយសង្គមក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩, ❹.សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចគ្រប់គ្រងការផ្គត់ផ្គង់ និងថ្លៃទំនិញយុទ្ធសាស្ត្រក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩។ លើសពីនេះ, វិធានការបន្ទាន់មួយចំនួនទៀត ត្រូវបានដាក់ចេញ ដូចជា (១) វិធានការសម្រួលផលប៉ះពាល់មកលើវិស័យទេសចរណ៍នៅក្នុង ខេត្តសៀមរាប, (២) វិធានការអន្តរាគមន៍បន្ទាន់របស់រាជរដ្ឋាភិបាលដើម្បីទ្រទ្រង់វិស័យទេសចរណ៍ វិស័យកាត់ដេរ សំលៀកបំពាក់ ស្បែកជើង និងកាបូប និងកំណើនសេដ្ឋកិច្ច, (៣) វិធានការសម្រួលផលប៉ះពាល់មកលើវិស័យសេដ្ឋកិច្ចកម្ពុជាពាក់ព័ន្ធសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, ជាដើម។



សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចប្រជុំ កាលពីថ្ងៃទី ៨ នៃមេសា ឆ្នាំ២០២០

*ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាសេនាធិការក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានកោះប្រជុំបន្ទាន់ដើម្បីរៀបចំក្រុមការងារដោះស្រាយនិងទប់ស្កាត់ និងវិធានការបន្ទាន់នានា ដើម្បីចូលរួមរក្សានូវលំនឹងសេដ្ឋកិច្ច, រក្សានូវសកម្មភាពអភិវឌ្ឍន៍, និងការធានានូវការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការជាប្រចាំ*

ថវិកាជាតិឆ្នាំ ២០២០ ត្រូវបានធ្វើវិចារណកម្មដោយកាត់បន្ថយផែនការចំណាយប្រមាណ ៥០% លើមុខសញ្ញាចំណាយពាក់ព័ន្ធបេសកកម្មក្រៅប្រទេសសម្រាប់គ្រប់ក្រសួង-ស្ថាប័ន និង២៥% សម្រាប់ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងពាណិជ្ជកម្ម, ១៥% លើមុខសញ្ញាចំណាយពាក់ព័ន្ធនឹងការទិញសម្ភារៈការិយាល័យនិងព័ត៌មានវិទ្យា សម្រាប់គ្រប់ក្រសួង-ស្ថាប័ន, ១៣% លើមុខសញ្ញាចំណាយប្រេងសម្រាប់គ្រប់ក្រសួង-ស្ថាប័ន និងការបង្កកការចំណាយផ្សេងៗទៀត។



សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារបច្ចេកទេសដើម្បីដោះស្រាយ និងទប់ស្កាត់វិបត្តិ នៃជំងឺរាតត្បាតកូវីដ-១៩

ទន្ទឹមនេះ, ដើម្បីជួយវិស័យដែលងាយទទួលរងឥទ្ធិពលពីវិបត្តិនៃជំងឺរាតត្បាតនេះ ជាពិសេសវិស័យទេសចរណ៍ សណ្ឋាគារ និងភោជនីយដ្ឋាន, រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ ក៏បានចេញនូវវិធានការផ្សេងៗទៀត ដើម្បីផ្តល់ការអនុគ្រោះ និងលើកទឹកចិត្តសម្រាប់ការប្រកបអាជីវកម្មផងដែរ។

វិបត្តិជំងឺរាតត្បាត Covid-19 គឺជាវិបត្តិសកល, កម្ពុជា ក៏បានជួបប្រទះ និងត្រូវបានស្ថាប័នអន្តរជាតិមួយចំនួន ដូចជារូបិយវត្ថុអន្តរជាតិ, ធនាគារពិភពលោក, និងធនាគារអភិវឌ្ឍន៍អាស៊ី បានព្យាករអំពីការធ្លាក់ចុះនូវអត្រាកំណើនសេដ្ឋកិច្ច ដូចប្រទេសក្នុងតំបន់ដទៃទៀត ប៉ុន្តែទោះជាយ៉ាងណា, ជាមួយនឹងវិធានការបុរេសកម្មដែលបានដាក់ចេញជាបន្តបន្ទាប់ ដើម្បីដោះស្រាយ និងទប់ស្កាត់ហានិភ័យ ដែលបង្កដោយវិបត្តិជំងឺនេះ, ត្រូវបានមជ្ឈដ្ឋានទូទៅរំពឹងថាកម្ពុជា នឹងអាចរួចផុតដោយជោគជ័យ ៕■

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.*

# ការផ្សារភ្ជាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសេវាសាធារណៈ

*រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា បានធ្លាប់ស្រមៃថាកម្ពុជានឹងមានប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយស្របតាមស្តង់ដារអន្តរជាតិ ដែលជួយកម្ពុជាឱ្យប្រែមុខមាត់ជាថ្មីម្តងទៀត។*

ការដាក់ចេញឱ្យអនុវត្តនូវកម្មវិធីកែទម្រង់ស៊ីជម្រៅ បានជំរុញឱ្យក្តីស្រមៃមួយនេះឈានទៅរកការពិតជាបណ្តើរៗ ជាក់ស្តែង ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងអត្រាកំណើនសេដ្ឋកិច្ចថេរ ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំក្នុងរយៈពេល ១ ទសវត្សចុងក្រោយ, ការចាកចេញពីភាពក្រីក្រជាបណ្តើរៗ, ជាប្រទេសឯកត្តករក្នុងពិភពលោកដែលបានកាត់ន្ថយភាពក្រីក្រពីរង្វង់ ៥០% នៅឆ្នាំ ១៩៩៨ រហូតមកត្រឹម រង្វង់ ៩% នៅឆ្នាំ ២០១៨ និងបន្តធ្លាក់ចុះជាបន្តបន្ទាប់ និងសុខមាលភាពប្រជាជនកាន់តែប្រសើរឡើង។




ការបន្តបាននូវភាពជឿទុកចិត្តបាននៃថវិកា បានផ្តល់នូវលទ្ធភាពគ្រប់គ្រាន់សម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់សុខុមាលភាព អ្នកផ្តល់សេវាសាធារណៈ មានដូចជា មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់លំដាប់ថ្នាក់ នៃគ្រប់ក្រសួង-ស្ថាប័ន តាមរយៈការបង្កើនប្រាក់បៀវត្ស ព្រមទាំងការលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋតាមរយៈការពង្រីក និងបង្កើនគុណភាពនៃការផ្តល់សេវាសាធារណៈ។

ក្នុងការឆ្លើយតបតម្រូវការសេវាសាធារណៈរបស់ប្រជាពលរដ្ឋកម្ពុជា, រាជរដ្ឋាភិបាលបានធ្វើការពង្រីកវិសាលភាព នៃការផ្តល់សេវាសាធារណៈ រហូតដល់ ២៥ រាជធានី-ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌ សម្រាប់ការផ្តល់សេវាសាធារណៈលើ ១៤ វិស័យ រួមមានវិស័យអប់រំ, សុខាភិបាល, កសិកម្ម, សំណង់, ឧស្សាហកម្ម, សាធារណការ, ពាណិជ្ជកម្ម, វប្បធម៌, ទេសចរណ៍, រ៉ែ និងថាមពល,

*ក្នុងការឆ្លើយតបតម្រូវការសេវាសាធារណៈរបស់ប្រជាពលរដ្ឋកម្ពុជា, រាជរដ្ឋាភិបាល បានធ្វើការពង្រីកវិសាលភាព នៃការផ្តល់សេវាសាធារណៈ រហូតដល់ ២៥ រាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក ខណ្ឌ សម្រាប់ការផ្តល់សេវាសាធារណៈលើ ១៤ វិស័យ*




សុរិយោដី, ការងាររដ្ឋបាល , នីត្យានុកូលកម្ម, និងអគ្រានុកូលដ្ឋាន ។ ការបំពាក់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ហៅកាត់ថា FMIS) សម្រាប់ការកត់ត្រា និងតាមដានក៏ត្រូវបានរៀបចំសម្រាប់ធានានូវគណនេយ្យភាពហិរញ្ញវត្ថុផងដែរ។ ការគិតគូររៀបចំនូវថវិកាកម្មវិធីផ្សារភ្ជាប់ទៅនឹងគោលនយោបាយជាតិ ក៏ត្រូវបានបន្តអនុវត្តប្រកបដោយសមត្ថភាព តម្លាភាព គុណភាព និងគណនេយ្យភាព នៅតាមគ្រប់ក្រសួង-ស្ថាប័ន ទាំងក្របខណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន បានចាប់ផ្តើមរៀបចំជាបណ្តើរៗនូវការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ទាំងក្របខណ្ឌចំណូល និងចំណាយ ដូចជា (១) ការផ្ទេរសិទ្ធិក្នុងការប្រមូលពន្ធមួយចំនួនទៅថ្នាក់ក្រោមជាតិ ដើម្បីបង្កើនប្រសិទ្ធភាព នៃការគ្រប់គ្រងនិងប្រមូលចំណូលនៅថ្នាក់មូលដ្ឋាន, (២) កញ្ចប់ថវិកាទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានបង្កើនជាលំដាប់ ដូចជា ការផ្ទេរកញ្ចប់ថវិកាទៅរដ្ឋបាលក្រុង ស្រុក បានបង្កើនពី ០,៨% នៃចំណូលចរន្តថវិកាថ្នាក់ជាតិ នៅឆ្នាំ ២០១៣ រហូតដល់ ១,២% នៃចំណូលចរន្តថវិកាថ្នាក់ជាតិ នៅឆ្នាំ ២០២០, (៣) ការផ្ទេរកញ្ចប់ថវិកាទៅរដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្កើនពី ២% នៃចំណូលចរន្តថវិកាថ្នាក់ជាតិ នៅឆ្នាំ ២០០៣ រហូតដល់ ៣,១% នៃចំណូលចរន្តថវិកាថ្នាក់ជាតិនៅឆ្នាំ ២០២១ ។ ដោយឡែក សម្រាប់សុខភាពរបស់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ក៏ត្រូវបានតាមដានជាប្រចាំតាមរយៈឧបករណ៍វាយតម្លៃអន្តរជាតិនានា ដែលបានធ្វើ ឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ បោះជំហានជាបន្តបន្ទាប់ទៅរកការគ្រប់គ្រងមួយប្រកបដោយគណនេយ្យភាពចំពោះសមិទ្ធកម្ម។

ជាការពិត ក្នុងបរិការណ៍នៃសុខសន្តិភាព ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អប្រសើរ ជំរុញឱ្យសុខុមាលភាពរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ហើយសេចក្តីត្រូវការនៃសេវាសាធារណៈ ស្របពេលដែលចំនួនប្រជាជនកម្ពុជា ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់។ ដូចនេះ រាជរដ្ឋាភិបាលបានបង្កើនចំណាយថ្នាក់ជាតិធៀបនឹង ផ.ស.ស. ក្នុងវិស័យសង្គមកិច្ច និងវិស័យសេដ្ឋកិច្ច កាន់តែខ្ពស់ដើម្បី ❶ ពង្រឹងគុណភាព និងពង្រីកវិសាលភាព នៃការផ្តល់សេវាសាធារណៈ, ❷ គាំទ្រការអនុវត្តគោលនយោបាយគាំពារសង្គម, ❸ គិតគូរនិងតំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ, និង ❹ ពន្លឿនការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, វិស័យថាមពល, និងវិស័យឌីជីថល ដើម្បីជំរុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ




រូបវន្ត សម្រាប់ភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច។

ជាលទ្ធផល សម្រាប់វិស័យអប់រំ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការអនុវត្តនូវកម្មវិធីលើកកម្ពស់វិស័យអប់រំជាច្រើន តួយ៉ាង កម្មវិធីអាហារូបករណ៍, កម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងការបញ្ជ្រាប STEM ចូលក្នុងកម្មវិធីអប់រំជាដើម។ យុវជនក្រីក្រ និងស្ត្រីក្នុងវិស័យអាទិភាព ក៏ត្រូវបានបន្តយកចិត្តទុកដាក់ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលលើវិស័យមួយចំនួន ដូចជា វិស័យសំណង់ ជួសជុលគ្រឿងចក្រ ព័ត៌មានវិទ្យា កម្មន្តសាល និងអគ្គិសនី ។ សម្រាប់វិស័យសុខាភិបាល, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមានអគារមន្ទីរពេទ្យ មណ្ឌលសុខភាព ឱសថស្ថាន សម្ភារៈបរិក្ខារពេទ្យ និងការធ្វើទំនើបកម្មបច្ចេកវិទ្យាក្នុងវិស័យសុខាភិបាល បុគ្គលិកជំនាញ បុគ្គលិកជំនាញឯកទេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការផ្តល់សេវាពិនិត្យ ព្យាបាល ឱ្យកាន់តែខិតជិតប្រជាពលរដ្ឋ និងបានទាន់ពេលវេលា ។ លើសពីនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយគាំពារសង្គមតាមរយៈកម្មវិធីមូលនិធិសមធម៌របបសន្តិសុខសង្គម (ហៅកាត់ថា បសស) និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីក្រីក្រមានផ្ទៃពោះ និងកូនអាយុក្រោម ២ ឆ្នាំ ដើម្បី

ទទួលបានសេវាឥតគិតថ្លៃ និងកម្មវិធីផ្សេងៗជាច្រើនទៀត។

ការពង្រីកវិសាលភាពធំជាងមុនលើការផ្គត់ផ្គង់ទឹក និងភ្លើង ជូនប្រជាពលរដ្ឋទាំងនៅទីប្រជុំជន និងតំបន់ដាច់ ស្រយាល និងការយកចិត្តទុកដាក់លើការវិនិយោគលើទំនប់វារីអគ្គិសនី, ការសាងសង់ស្ថានីយអគ្គិសនី, និង ជាពិសេសប្រព័ន្ធសូឡា និងថាមពលដែលកកើតឡើងវិញ, ការស្តារឡើងវិញលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលបានខូចខាតជាច្រើន និងហេដ្ឋារចនាសម្ព័ន្ធថ្មីៗដូចជា ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ការបើកឱ្យដំណើរការឡើង វិញខ្សែផ្លូវរថភ្លើងទិសខាងជើងពីភ្នំពេញទៅប៉ោយប៉ែត ការពង្រីងព្រលានយន្តហោះ និងកំពង់ផែ ព្រមទាំងផែនការវិនិយោគថ្មីៗលើបច្ចេកវិទ្យាជំនាន់ថ្មី (5G) លើការពង្រីកវិសាលភាពអ៊ីនធឺណេត ឱ្យគ្របដណ្តប់ដល់តំបន់ដាច់ស្រយាល ។ សេវាចុះបញ្ជីយានយន្តកាន់តែផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋកម្ពុជា ដែលបានជំរុញឱ្យមានកំណើន នៃការចុះ បញ្ជីយានយន្តជាច្រើន។ ក្នុងបរិការណ៍ នៃបដិវត្តន៍ឧស្សាហកម្ម ៤.០ បានបង្កបរិស្ថានអំណោយផលដល់នវានុវត្តន៍ ដូចជាការអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីបង្កើតធុរកិច្ចថ្មីៗ, និងការអភិវឌ្ឍយ៉ាងឆាប់រហ័សនូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាផ្សេងៗទៀត ។

*ក្នុងបរិការណ៍នៃសុខសន្តិភាព ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានល្អប្រសើរ ជំរុញឱ្យសុខុមាលភាពរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ហើយសេចក្តីត្រូវការនៃសេវាសាធារណៈ ស្របពេលដែលចំនួនប្រជាជនកម្ពុជា ក៏មានការកើនឡើងគួរឱ្យកត់សម្គាល់*



*ការស្តារឡើងវិញលើហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត និងហេដ្ឋារចនាសម្ព័ន្ធថ្មីៗដូចជា ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ការបើកឱ្យដំណើរការឡើង វិញខ្សែផ្លូវរថភ្លើងទិសខាងជើងពីភ្នំពេញទៅប៉ោយប៉ែត ការពង្រីងព្រលានយន្តហោះ និងកំពង់ផែ។*

ថ្មីៗបន្ថែមទៀត ដូចជា ការជួសជុល និងកែលម្អផ្លូវថ្នល់ដែលខូចខាត, ការស្តាបនាស្ថានអាកាស, ការកែលម្អអាកាសយានដ្ឋាន, ការបង្កើនសមត្ថភាពផលិត និងផ្គត់ផ្គង់អគ្គិសនី, ការប្រើប្រាស់ទូរគមនាគមន៍និងអ៊ីនធើណែត, សេវាដឹកជញ្ជូនសាធារណៈតាមរថយន្តក្រុង, និងការបង្កើនភាពប្រកួតប្រជែងក្នុងវិស័យសំណង់ ជាដើម។ ការអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋា-

ជារួម, សមិទ្ធផលទាំងនេះ កើតចេញពីឆន្ទៈដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជា គឺ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំ និងចង្អុលបង្ហាញទៅគ្រប់ក្រសួងស្ថាប័នជំនាញ ឱ្យតម្កល់ផលប្រយោជន៍ប្រជាពលរដ្ឋជាធំ ហើយបានកំណត់ទុកនូវចក្ខុវិស័យវិជ្ជមានសម្រាប់កម្ពុជាឆ្ពោះទៅកាន់ប្រទេសចំណូលខ្ពស់នៅឆ្នាំ ២០៥០ តាមរយៈការចូលរួមចំណែកនៃប្រសិទ្ធភាពនៃ "កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" និងកម្មវិធីកែទម្រង់ផ្សេងៗទៀត ៕■

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.*





# ដំណើរឆ្ពោះទៅប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ក្នុងគោលបំណងកែប្រែជាជំហានៗ នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅឧត្តមានុវត្តន៍អន្តរជាតិ ឬផ្លាស់ប្តូរជាបណ្តើរៗ ពី "ប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ" ទៅរក "ប្រព័ន្ធថវិកាផ្អែកលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ" ដោយប្រកាន់យកអភិក្រមជាខឿន និងបែងចែកជា ៤ ដំណាក់កាល ។*

ដំណាក់កាលទី១ "**ភាពជឿទុកចិត្ត នៃថវិកា**" ដែលអនុវត្តចាប់ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៨ បានបញ្ចប់នូវស្ថានភាពកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ មកជាអតិរេកសាច់ប្រាក់ តាមរយៈការលុបបំបាត់ទាំងស្រុងនូវបំណុលកកស្ទះនៅរតនាគារជាតិ ដែលជាហេតុធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា ដោះស្រាយបាននូវការបើកប្រាក់បៀវត្ស បានទៀងទាត់ និងទាន់ពេលវេលា ជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ។ ការបង្កើតគណនីទោលនៅរតនាគារជាតិដែលជា ការប្រមូលផ្តុំគណនីទាំងអស់របស់រាជរដ្ឋាភិបាល បានក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់បោះជំហានទៅរកដំណាក់កាលទី ២។ ដំណាក់កាលទី ២ "**បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ**" ត្រូវបានអនុវត្តពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៥ ដោយមានការកែលម្អជា ច្រើនលើនីតិវិធីអនុវត្តថវិកា ជាពិសេស ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី ព្រមទាំងការដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)[1] ។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ថិតនៅដំណាក់កាលទី ៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ដែលត្រូវបានអនុវត្តចាប់ពីឆ្នាំ ២០១៦ រហូតដល់ឆ្នាំ ២០២០ ក្នុងគោលបំណងផ្លាស់ប្តូរជាបណ្តើរៗឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី[2] និងការអនុវត្តអង្គភាពថវិកា។ ដំណាក់កាលទី ៤ "**គណនេយ្យភាពសមិទ្ធកម្ម**" គ្រោងអនុវត្តចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៥ ដោយត្រូវសម្រេច ឱ្យបាននូវប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្ម ។

## ❖ ទិសដៅនៃការកែទម្រង់ប្រព័ន្ធថវិកា

### ➢ ការកំណត់ទិសដៅត្រឹមឆ្នាំ ២០២០

នៅខែមិថុនា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានអនុម័តឯកសារ "**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០**" ដើម្បីជាមគ្គុទេសក៍សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣។ ឯកសារទស្សនាទាននេះ បានកំណត់គោលបំណងផ្លាស់ប្តូរជាបណ្តើរៗ និងជាជំហានៗ ពី "ប្រព័ន្ធថវិកា ផ្អែកលើធាតុចូល និងមជ្ឈការ" ទៅរក "ប្រព័ន្ធថវិកាផ្អែកលើសមិទ្ធកម្មនិងវិមជ្ឈការ" ត្រឹមឆ្នាំ ២០២០ ។ ក្នុងទិសដៅនេះ ឯកសារទស្សនាទានបានកំណត់គោលបំណង និងវិសាលភាពនៃការកែទម្រង់ក្នុងក្របខណ្ឌនៃវដ្តថវិកា រួមមាន ការរៀបចំថវិកា ការ



[1] ត្រឹមឆ្នាំ២០២០ ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់រតនាគារទាំង២៥ រាជធានី-ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២៥ រាជធានី-ខេត្ត និងគ្រប់ក្រសួង-ស្ថាប័ន ។

[2] ការអនុវត្តថវិកាកម្មវិធី ដែលជាស្នូលនៃដំណាក់កាលទី៣ ត្រូវបានដាក់ឱ្យអនុវត្តពេញលេញនៅគ្រប់ក្រសួង-ស្ថាប័នត្រឹមឆ្នាំ២០១៨ និងត្រូវបានដាក់ឱ្យអនុវត្តនៅរដ្ឋបាលខេត្តចំនួន ១៨ ត្រឹមឆ្នាំ២០១៩ ហើយដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នៅគ្រប់រដ្ឋបាលរាជធានី-ខេត្តត្រឹមឆ្នាំ២០២១ ។

# ការដាក់អនុវត្តនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS

*ការបើកផ្តល់បៀវត្ស និងចំណាយបន្ទុកបុគ្គលិកដែលមានគោលរបបកំណត់ច្បាស់លាស់ដូចជា ឧបត្ថម្ភអ្នកសម្រាលកូន, ឧបត្ថម្ភនិវត្តជន, ឧបត្ថម្ភអ្នកសុំឈប់ពីការងារ ជាដើម ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុង ដោយមិនមានបញ្ជូនឯកសារជាក្រដាសពីដំណាក់កាលមួយទៅមួយទៀតនោះទេ ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ នេះតទៅ ។*

អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងផ្អែកលើផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ២០២០-២០២៥ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុម័តកាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាប់ផ្តើមអនុវត្តសាកល្បងជំហានដំបូងជាគំរូមុនគេនូវនីតិវិធីតម្រង់ទិសថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ នេះតទៅមុននឹងឈានទៅអនុវត្តនីតិវិធីផ្សេងៗទៀត ក្នុងក្របខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធ FMIS និងឈានទៅអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន ។

ជំហានដំបូងនេះ អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ និងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិនៅថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានរតនាគារជាតិ នឹងត្រូវចូលរួមអនុវត្តនីតិវិធីតម្រង់ទិសថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ ដែលរួមមាន បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារ បៀវត្សមូលដ្ឋានសម្រាប់បុគ្គលិកជាប់កិច្ចសន្យា ឧបត្ថម្ភអ្នកសម្រាលកូន ឧបត្ថម្ភនិវត្តជន ឧបត្ថម្ភអ្នកសុំលាឈប់ពីការងារ ឧបត្ថម្ភកូនអាយុ ២០ឆ្នាំចុះ ជាដើម។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
លេខ ០០៨

សេចក្តីណែនាំ
ស្តីពី
ការអនុវត្តនីតិវិធីថ្មីសម្រាប់ការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ដែលមានគោលរបបកំណត់ច្បាស់លាស់ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

១.នីតិវិធីអនុវត្តការងារថ្មីខាងលើ គ្របដណ្តប់លើមុខសញ្ញាចំណាយដែលមានលេខអនុគណនីដូចខាងក្រោម៖

| អនុគណនី | បរិយាយ |
|---|---|
| 64014 | ប្រាក់បំណាច់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ |
| 64016 | លាភការទីប្រឹក្សា |
| 64018 | លាភការអ្នកជំនួយការ |
| 64021 | បៀវត្សមូលដ្ឋាន |
| 64022 | ប្រាក់បំណាច់មុខងារ |
| 64041 | បៀវត្សមូលដ្ឋាន បុគ្គលិកជាប់កិច្ចសន្យា |
| 64052 | អ្នកសម្រាលកូន |
| 64054 | ឧបត្ថម្ភនិវត្តជន |
| 64055 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ |
| 64061 | កូនមានអាយុចាប់ពី២០ឆ្នាំចុះ |
| 64063 | ប្រាក់បំណាច់អ្នកក្នុងបន្ទុក |
| 64981 | បន្ទុកបុគ្គលិកផ្សេងៗទៀត |

- 1 -










*ការអនុវត្តនីតិវិធីតម្រង់ទិសថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុងនេះ បានចូលរួមចំណែកដ៏ធំធេងក្នុងការកាត់បន្ថយចំណាយរដ្ឋបាល (មិនប្រើប្រាស់ក្រដាស់ និងឧបករណ៍សម្ភារការិយាល័យមួយចំនួន) ចំណេញពេលវេលា និងពង្រឹងតម្លាភាព ពង្រឹងគណនេយ្យភាព និងបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃការអនុវត្តថវិកា។*

នៅក្នុងការអនុវត្តនីតិវិធីថ្មីនេះ ឯកសារជាក្រដាសនានា រួមមាន សំណុំឯកសារអាណត្តិបើកប្រាក់ និងឯកសារយោងផ្សេងៗទៀតមិនត្រូវបានរៀបចំចុះហត្ថលេខា និងបញ្ជូនពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតឡើយនៅតាមអង្គភាពទាំងឡាយដែលប្រើប្រាស់ប្រព័ន្ធ FMIS ចាប់ពី

## សង្ខេបនីតិវិធីទូទាត់ចំណាយបៀវត្សរ៍សម្រួលថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុង




ដំណាក់កាលអង្គភាពថវិកា រហូតដល់ដំណាក់កាលអគ្គនាយកដ្ឋានរតនាគារជាតិ ដោយអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុងភ្ជាប់ជាមួយនឹងការស្កេនឯកសារយោងពីអង្គភាពថវិកា។ ការអនុវត្តនីតិវិធីតម្រង់ទិសថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុងនេះ បានចូលរួមចំណែកដ៏ធំធេងក្នុងការកាត់បន្ថយចំណាយរដ្ឋបាល (មិនប្រើប្រាស់ក្រដាស និងឧបករណ៍សម្ភារការិយាល័យមួយចំនួន) ចំណេញពេលវេលា (មិនប្រើពេលវេលារត់ឯកសារឆ្លងពីដំណាក់កាលមួយទៅមួយ) និងពង្រឹងតម្លាភាព (លំហូរនៃប្រតិបត្តិការចំណាយថវិកាបង្ហាញក្នុងប្រព័ន្ធ FMIS) ពង្រឹងគណនេយ្យភាព និងបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការអនុវត្តថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានចូលរួមចំណែកក្នុងការអនុវត្តគោលការណ៍គម្លាតសង្គម ព្រមទាំងចូលរួមធ្វើ ឱ្យប្រទេសកម្ពុជាប្រែក្លាយទៅជារដ្ឋាភិបាលឌីជីថលក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ក្នុងបរិការណ៍បដិវត្តន៍ឧស្សាហកម្មទី ៤ ផងដែរ ។

នីតិវិធីអនុវត្តការងារផ្សេងៗដែលត្រូវជ្រើសរើសយកមកធ្វើការសិក្សាជាបន្តបន្ទាប់ និងអនុវត្តនៅក្នុងផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS មាន ៤ ប្រភេទគឺ÷ ១.នីតិវិធីអនុវត្តការងារពាក់ព័ន្ធធានាចំណាយ និងទូទាត់ចំណាយថវិកា, ២.នីតិវិធីអនុវត្តការងារលើការធ្វើចលនាឥណទានចំណាយថវិកា, ៣.នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងការកត់ត្រាចំណូលថវិកា និង ៤.នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម ។

ការតម្រឹម និងបន្ស៊ីជំហាននៃនីតិវិធីអនុវត្តការងារបច្ចុប្បន្នរវាងជំហាននៅខាងក្រៅ និងជំហាននៅក្នុងប្រព័ន្ធ FMIS ក្នុងគោលដៅកាត់បន្ថយជំហាននៅខាងក្រៅប្រព័ន្ធ FMIS ជាអតិបរមា ឈានទៅកាន់ការអនុវត្តជំហាននៃនីតិវិធីអនុវត្តការងារនៅខាងក្នុងប្រព័ន្ធ FMIS ទាំងស្រុង។ ការតម្រឹម និងបន្ស៊ីជំហាននៃនីតិវិធីអនុវត្តការងារខាងក្រៅ និងខាងក្នុងប្រព័ន្ធ FMIS ត្រូវឈរលើមូលដ្ឋានដូចខាងក្រោម÷

- នីតិវិធីអនុវត្តការងារទាំងអស់ចែកចេញជាដំណាក់កាល និងជំហាន



- កំណត់**ជំហាន**នៃនីតិវិធីអនុវត្តការងារជាបី (០៣) ប្រភេទ ទាំងជំហានខាងក្នុង និងជំហានខាងក្រៅប្រព័ន្ធ FMIS គឺ ១-រៀបចំ, ២-ត្រួតពិនិត្យ និង ៣-អនុម័តឯកសារ(សម្រាប់ជំហានខាងក្រៅប្រព័ន្ធ FMIS) និង ១-បង្កើត, ២-ត្រួតពិនិត្យ និង ៣-អនុម័តប្រតិបត្តិការ(សម្រាប់ជំហានខាងក្នុងប្រព័ន្ធ FMIS) (1-Add, 2-Review, 3-Approve)
- កំណត់កម្រិតហានិភ័យឬវេទយិតភាពនៃនីតិវិធីអនុវត្តការងារជា បី (០៣) កម្រិត នៅតាមដំណាក់កាលនីមួយៗ ជាក់ស្តែងនៃនីតិវិធីអនុវត្តការងារ គឺ **កម្រិត១ ឬទាប, កម្រិត២ ឬមធ្យម, កម្រិត៣ ឬខ្ពស់** ៕■

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*





# អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ

*«យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥» ត្រូវបានពិនិត្យ និងយល់ព្រមដោយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវបានសម្តេចតេជោនាយករដ្ឋមន្ត្រីអនុម័តកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ និងប្រកាសដាក់ឱ្យអនុវត្តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩។*

យុទ្ធសាស្ត្រនេះមានគោលបំណងបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិនៅមុនដំណាច់ឆ្នាំ២០២៥ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។



កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ លើការប្រកាសដាក់ឱ្យអនុវត្ត យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ

អនុលោមតាមផែនការសកម្មភាពរួមដែលបានដាក់ចេញក្រោម «**យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**», កិច្ចការអាទិភាពបន្ទាន់ចំពោះមុខ ដែលត្រូវសម្រេចឱ្យបានដើម្បីបើកផ្លូវទៅបន្តអនុវត្តសកម្មភាពផ្សេងៗទៀត គឺការរៀបចំ និងដាក់ឱ្យអនុវត្ត «**អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ**»។ ដោយយល់ឃើញពីភាពចាំបាច់ និងបន្ទាន់នៃការងារនេះ, ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចអនុម័តដាក់ឱ្យអនុវត្ត «**អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ**» នៅថ្ងៃទី២៥ ខែមិនា ឆ្នាំ២០២០ កន្លងទៅ។ អនុក្រឹត្យនេះ ត្រូវបានបែងចែកជា ៧ ជំពូក (១៥ មាត្រា)÷ (១) បទប្បញ្ញត្តិទូទៅ, (២) គោលការណ៍ និងលក្ខខណ្ឌតម្រូវសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ, (៣) វដ្តនៃគម្រោងវិនិយោគសាធារណៈ, (៤) តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈនិងរដ្ឋបាលថ្នាក់ក្រោមជាតិ, (៥) នីតិវិធីប្រតិបត្តិការនៃការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ, (៦) កាតព្វកិច្ចរបាយការណ៍, និង (៧) អវសានប្បញ្ញត្តិ ព្រមទាំងភ្ជាប់ជាមួយនូវសទ្ទានុក្រម ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈមានគោលបំណងធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅតាមដំណាក់កាលនៃវដ្តគម្រោង និងពីគ្រប់ប្រភពហិរញ្ញប្បទាន សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសមធមិសង្គម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អនុក្រឹត្យនេះ ជាអនុក្រឹត្យគោលមានគោលដៅកំណត់គោលការណ៍ជាសារវន្ត និងប្រព័ន្ធនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ជាអាទិ៍ដូចខាងក្រោម÷

- គោលការណ៍រួមសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល។
- ដំណាក់កាលរួមនៃវដ្តគម្រោងវិនិយោគសាធារណៈ
- តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់ដំណាក់កាល នៃវដ្តគម្រោង
- ការផ្សារភ្ជាប់ រវាងផែនការវិនិយោគសាធារណៈ ជាមួយនឹងថវិកានីយកម្មការវិនិយោគសាធារណៈ
- នីតិវិធីប្រតិបត្តិការ នៃការរៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោង
- កាតព្វកិច្ចរបាយការណ៍ ។

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្ដប់លើការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយ ថវិកាជាតិ, ថវិកាដៃគូ, យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, ឥណទានពាណិជ្ជកម្ម, ការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ, ប្រភពហិរញ្ញប្បទានចម្រុះ, និងថវិកាអង្គភាពសាធារណៈ។ នៅក្នុងអនុក្រឹត្យនេះ, វដ្តនៃគម្រោងវិនិយោគសាធារណៈ ត្រូវមាន ៨ ដំណាក់កាល ដូចខាងក្រោម÷

**ដំណាក់កាលទី១** ការធ្វើអត្តសញ្ញាណកម្ម និងការរៀបចំគម្រោងបឋម

- កំណត់អត្តសញ្ញាណគម្រោង រៀបចំសំណើគម្រោងបឋម ឬឯកសារទស្សនទានគម្រោង
- អនុលោមតាមគោលនយោបាយជាតិ និងក្របខណ្ឌថវិការយៈពេលមធ្យម
- ធ្វើអាទិភាវូបនីយកម្មសំណើគម្រោងវិនិយោគ សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការវិនិយោគសាធារណៈ

**ដំណាក់កាលទី២** ការសិក្សាសមិទ្ធិលទ្ធភាព និងការវាយតម្លៃសំណើគម្រោង

- សិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃគម្រោងលើទិដ្ឋភាពពាក់ព័ន្ធ
- គោរពតាមគោលការណ៍ស្ដីពីការសិក្សាសមិទ្ធិលទ្ធភាព និងវាយតម្លៃសំណើគម្រោង ដែលមានជាធរមាន

**ដំណាក់កាលទី៣** ការពិនិត្យ និងវាយតម្លៃលើសំណើគម្រោង

- ពិនិត្យផ្ទៀងផ្ទាត់ឡើងវិញលើការវាយតម្លៃសំណើគម្រោង

**ដំណាក់កាលទី៤** ការជ្រើសរើសសំណើគម្រោង និងថវិកានីយកម្ម

- កំណត់ប្រភពហិរញ្ញប្បទាន
- ធ្វើថវិកានីយកម្ម
- តារាងសង្ខេបអំពីបញ្ជីគម្រោងវិនិយោគសាធារណៈដែលត្រូវបានជ្រើសរើស សម្រាប់ការធ្វើថវិកានីយកម្ម ត្រូវភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុ។

**ដំណាក់កាលទី៥** ការគ្រប់គ្រង និងការអនុវត្តគម្រោង

- ចាប់ផ្ដើមអនុវត្តកិច្ចលទ្ធកម្ម រាប់ទាំងការរៀបចំផែនការ ការអនុវត្តនីតិវិធីលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា
- ករណីគម្រោងវិនិយោគដែលមានទំហំមធ្យម ឬធំ ត្រូវរៀបចំក្នុងក្របខ័ណ្ឌនៃកញ្ចប់ថវិកាពហុឆ្នាំ

**ដំណាក់កាលទី៦** ការកែសម្រួលគម្រោង

- តាមដានការអនុវត្តគម្រោង ដោយត្រូវផ្ទៀងផ្ទាត់វឌ្ឍនភាពនៃការអនុវត្តគម្រោង ទៅនឹងផែនការអនុវត្តគម្រោង
- កែសម្រួលគម្រោង តាមការចាំបាច់

**ដំណាក់កាលទី៧** ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាងសង់ក្រោមគម្រោង

- ត្រួតពិនិត្យ និងវាយតម្លៃបញ្ចប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ
- ប្រគល់-ទទួល
- ដាក់ឱ្យប្រើប្រាស់
- ចុះបញ្ជីជាទ្រព្យសម្បត្តិរដ្ឋ

**ដំណាក់កាលទី៨** ការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង

- ចាត់ចែងរៀបចំការវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង
- ចងក្រងជារបាយការណ៍ស្ដីពីលទ្ធផលសម្រេចបាន ព្រមទាំងបញ្ហាប្រឈមនៃការអនុវត្តគម្រោង
- ទុកជាបទពិសោធក្នុងការរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈក្រោយៗទៀត

អនុក្រឹត្យនេះ ក៏សង្កត់ធ្ងន់លើការបង្កើតយន្តការបុរេថវិកានីយកម្មការវិនិយោគសាធារណៈ នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបំពេញមុខងារយ៉ាងសំខាន់ជាទ្វារបាលនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈដោយនឹងធ្វើការ (១) ពិនិត្យវាយតម្លៃសំណើគម្រោង ធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងតម្លៃ និងហានិភ័យនៃគម្រោង និង (២) ជ្រើសរើសគម្រោងដើម្បីធានានូវភាពឆ្លើយតបនឹងតម្រូវការ

*យុទ្ធសាស្ត្រនេះមានគោលបំណងបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិនៅមុនដំណាច់ឆ្នាំ ២០២៥ ដែលធានាបាននូវភាពឆ្លើយតប, ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍ជាក់ស្ដែងស្របតាមបរិកាណ៍ជាក់ស្ដែងរបស់កម្ពុជា*

អាទិភាពនៃផែនការយុទ្ធសាស្ត្រតាមវិស័យ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ក្នុងយន្តការនេះ ក៏ដាក់ចេញនូវបណ្ដាគោលការណ៍ជាសារវន្តសម្រាប់ការជ្រើសរើសគម្រោងព្រមទាំងគោលការណ៍ដោយឡែកសម្រាប់ប្រភេទគម្រោងដែលមានចរិតស្មុគស្មាញ និងវេទយិតភាពខ្ពស់ជាពិសេសចំពោះគម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយ«**ការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ**» ដែលជាគោលការណ៍តម្រូវឱ្យអនុវត្តតាមគោលការណ៍រួមនៃការគ្រប់គ្រងការវិនិយោគសាធារណៈ។

បន្ទាប់ពីការអនុម័តដាក់ឱ្យប្រើប្រាស់នូវអនុក្រឹត្យស្ដីពីការគ្រប់គ្រងការវិនិយោគសាធារណៈ, អនុក្រឹត្យ ឬប្រកាសស្ដីពីនីតិវិធីប្រតិបត្តិការនៃការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈតាមប្រភពហិរញ្ញប្បទាន និងតាមកម្រិតរដ្ឋបាល ព្រមទាំងគោលការណ៍ណែនាំរួមលម្អិតស្ដីពីវដ្តនៃគម្រោងវិនិយោគសាធារណៈនឹងត្រូវរៀបចំ និងដាក់ឱ្យអនុវត្ត ដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពពេញលេញនៃការគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា៕■

*រៀបចំដោយ÷ ផ្នែកអនុវត្តថវិកា នៃ អ.គ.ប.*





# ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥

*ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥ ត្រូវបានទទួលការឯកភាព និងដាក់ឱ្យអនុវត្តក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០។*

យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ជាសមាសភាគដ៏សំខាន់មួយនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ ក្រោមក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលត្រូវបានរៀបចំឡើងស្របតាមបរិការណ៍ជាក់ស្ដែងរបស់កម្ពុជា និងឧត្តមានុវត្តន៍ជាអន្តរជាតិហើយបានដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រគន្លឹះៗនិងផែនការសកម្មភាពរួមដើម្បីអនុវត្តស្របតាមអភិក្រម «**ប្រយ័ត្នប្រយែង, សន្សឹមៗ, ឈរលើគោលការណ៍ប្រាកដនិយមនិងជាក់ស្ដែងនិយម, ទន់ភ្លន់, និងរៀនផង-ធ្វើផង**»។ ក្នុងគោលបំណងធានាបាននូវការអនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ចាំបាច់ត្រូវមានផែនការសកម្មភាពលម្អិត ដែលកំណត់ច្បាស់លាស់អំពីសូចនាករសមិទ្ធកម្មគន្លឹះ, ក្របខណ្ឌពេលវេលាអនុវត្ត, និងអង្គភាពទទួលខុសត្រូវ។

### ❖ ក្របខណ្ឌរួម នៃផែនការសកម្មភាពលម្អិត

ផែនការសកម្មភាពលម្អិតនេះ ត្រូវបានរៀបចំឡើងដោយអនុលោមតាមផែនការសកម្មភាពរួមនៃយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥។ ទន្ទឹមនេះ, ការវាយតម្លៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (Public Investment Managment Assessment - PIMA) ជាការងារកែទម្រង់គន្លឹះដ៏សំខាន់មួយទៀត សម្រាប់ជាធាតុចូលបន្ថែមក្នុងការវិភាគ និងកំណត់អំពីភាពខ្លាំង, ភាពខ្សោយ, និងផ្ដល់អនុសាសន៍លើការរៀបចំផែនការសកម្មភាព ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការវិនិយោគ



សាធារណៈ។ លើមូលដ្ឋាននេះ, ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ដាក់ចេញនូវការងារកែទម្រង់គន្លឹះចំនួន ១៤, សូចនាករសមិទ្ធកម្មគន្លឹះចំនួន ៣៨, ចង្កោមសកម្មភាពចំនួន ៣៨, និងសកម្មភាពចំនួន ៧៩ ដែលបានបញ្ជាក់អំពីអង្គភាពទទួលបន្ទុក និងក្របខណ្ឌពេលវេលាជាក់លាក់។ ដូចខាងក្រោមនេះ ជាការងារកែទម្រង់គន្លឹះទាំង ១៤ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពនេះ÷ *(តារាង១)* ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព និងភាព

*ការងារកែទម្រង់គន្លឹះនៃផែនការសកម្មភាពលម្អិតនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុង «ផែនការសកម្មភាពរួម-CAP» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ២០១៩-២០២៥ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។*

ជោគជ័យនៃការដ្ឋានកែទម្រង់, ការងារកែទម្រង់គន្លឹះនៃផែនការសកម្មភាពលម្អិតនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុង «ផែនការសកម្មភាពរួម - CAP» នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

### ❖ យន្តការសម្របសម្រួល តាមដាន និងវាយតម្លៃការអនុវត្តផែនការសកម្មភាព

ដើម្បីធានាបាននូវប្រសិទ្ធភាព នៃការអនុវត្ត«**ផែនការសកម្មភាពលម្អិតសម្រាប់អនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥**» ចាំបាច់ត្រូវមានយន្តការចំនួន ៣ ដូចខាងក្រោម÷

➢ យន្តការសម្របសម្រួលកម្រិតបច្ចេកទេស÷ អគ្គនាយកដ្ឋានសហប្រតិបត្តិការ

| ល.រ. | ការងារកែទម្រង់គន្លឹះៗ | អង្គភាពទទួលបន្ទុក |
|---|---|---|
| ១ | សិក្សា និងពិនិត្យឡើងវិញលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ | អគ្គ.ថវិកា |
| ២ | រៀបចំ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈ | អ.គ.ហ./អ.ស.ប. |
| ៣ | ពង្រឹងការអនុវត្ត **«គោលការណ៍ស្តីពីការកំណត់អត្តសញ្ញាណកម្ម និងអាទិភាវូបនីយកម្មគម្រោង»** | ក្រសួងផែនការ |
| ៤ | រៀបចំ និងដាក់ឱ្យអនុវត្ត **«គោលការណ៍ណែនាំស្តីពីការរៀបចំសំណើគម្រោង»** ឬ **«គោលការណ៍ណែនាំរួមលម្អិតស្តីពីវដ្តនៃគម្រោងវិនិយោគសាធារណៈ»** | អ.គ.ហ./អ.ស.ប. |
| ៥ | ការរៀបចំកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ | អគ្គ.ហិ.ថ្នាក់ក្រោមជាតិ |
| ៦ | ពង្រឹង និងកែសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដើម្បីធ្វើសមាហរណកម្មថវិកានីយកម្មពីគ្រប់ប្រភព និងពីគ្រប់មុខសញ្ញាចំណាយ | អគ្គ.ថវិកា |
| ៧ | បង្កើតយន្តការបុរេថវិកានីយកម្មការវិនិយោគសាធារណៈ សម្រាប់បំពេញមុខងារទ្វារបាលកិច្ចនៃការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ | អគ្គ.គោលនយោបាយ |
| ៨ | រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈតាមប្រភពហិរញ្ញប្បទាន | អគ្គ.ថវិកា, អគ្គ.ហិ.ថ្នាក់ក្រោមជាតិ, អ.ស.ប. |
| ៩ | រៀបចំក្របខ័ណ្ឌគតិយុត្តដូចមានចែងក្នុង **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០"** | អង្គភាព PPP |
| ១០ | រៀបចំ និងដាក់ឱ្យអនុវត្តគោលការណ៍ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ | អគ្គ.ថវិកា |
| ១១ | រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ | អគ្គ.គោលនយោបាយ |
| ១២ | រៀបចំ និងដាក់ឱ្យអនុវត្តយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធលទ្ធភាព និងរៀបចំគម្រោង | អ.គ.ហ./អ.ស.ប., អគ្គ.ថវិកា, អង្គភាព PPP |
| ១៣ | រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស | វិ.សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ១៤ | ត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈនៅកម្ពុជា | អ.គ.ហ./អ.ស.ប. |

តារាង១

អន្តរជាតិ និង គ្រប់គ្រងបំណុលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភារកិច្ចសម្របសម្រួល ជំរុញ និងដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តផែនការសកម្មភាពក្នុងកម្រិតបច្ចេកទេស។

➢ **យន្តការសម្របសម្រួលកម្រិតប្រតិបត្តិការ÷** ក្នុងករណីចាំបាច់, រដ្ឋលេខាធិការទទួលបន្ទុកនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចដឹកនាំការសម្របសម្រួល ជំរុញ និងដោះស្រាយបញ្ហាប្រឈមក្នុងកម្រិត អន្តរអគ្គនាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធ ក្រោមឱវាទ កសហវ និងអន្តរក្រសួង ស្ថាប័នពាក់ព័ន្ធ។ ក្នុងករណីមានវេទយិតភាព, ត្រូវស្នើសុំការសម្រេចពីគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និងនាយករដ្ឋមន្ត្រី។

➢ **យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ÷** អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានភារកិច្ចត្រួតពិនិត្យ និងធានាថារាល់សកម្មភាពលម្អិតនីមួយៗត្រូវបានដាក់បញ្ចូលត្រឹមត្រូវ និងតាមពេលវេលាកំណត់ ព្រមទាំងធានាពីការផ្តល់នូវធនធានសមស្របនៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តសកម្មភាពទាំងនេះ។ ទន្ទឹមនេះ, អគ្គនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្តីពីការរៀបចំ និងការអនុវត្តផែនការសកម្មភាពសម្រាប់អនុវត្តការងារកែទម្រង់ដែលមានចែង ក្នុងវិធានការជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន និងផ្ញើជូនអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបូកសរុប និងរាយការណ៍ជូនគណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

ជារួម, ការចូលរួម និងសហការអនុវត្តនូវផែនការសកម្មភាពលម្អិត ប្រកបដោយបុរេសកម្ម សកម្ម អន្តរសកម្ម ការប្តេជ្ញាចិត្ត និងស្មារតីទទួលខុសត្រូវខ្ពស់ របស់អគ្គនាយកដ្ឋាន ឬអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ គឺជាបុរេលក្ខខណ្ឌនៃភាពជោគជ័យក្នុងការអនុវត្ត «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥» សម្រាប់ឈានទៅបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិនៅមុនដំណាច់ឆ្នាំ ២០២៥ ។ ផែនការសកម្មភាពលម្អិតនេះត្រូវបានចាត់ទុកជា **«ឯកសាររស់»** ដែលអាចនឹងត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មប្រចាំឆ្នាំ ៕■ *រៀបចំដោយ÷ ផ្នែកអនុវត្តថវិកា នៃ អ.គ.ហ.*





# វិធីសាស្ត្រការវាយតម្លៃប្រសិទ្ធភាពរបស់រដ្ឋបាលសារពើពន្ធ ដោយប្រើប្រាស់ "ឧបករណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធ TADAT

*ការកែទម្រង់វិស័យពន្ធដារ គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Reform Program- PFMRP)។*

វឌ្ឍនភាពគួរឱ្យកត់សម្គាល់និងជាទីមោទនៈនៃការអនុវត្តការកែទម្រង់វិស័យពន្ធដារមានដូចជា÷ ❶. ធានាបាននូវប្រសិទ្ធភាព និងនិរន្តរភាពក្នុងការគ្រប់គ្រង និងប្រមូលចំណូលពន្ធដារ ដែលសម្រេចបានលើសផែនការជាច្រើនឆ្នាំជាប់ៗគ្នា ។ ជាក់ស្តែងក្នុងរយៈពេល ០៦ ឆ្នាំចុងក្រោយនេះ (២០១៤-២០១៩) ចំណូលពន្ធដារបានកើនឡើងប្រមាណ ១១% ជារៀងរាល់ឆ្នាំ ធៀបទៅនឹងផែនការប្រមូលដែលកំណត់ដោយច្បាប់ (ពី៤ ២៦៧ ប៊ីលានរៀលនៅឆ្នាំ២០១៤ ទៅ ១០ ៧៩៦,៦៥ប៊ីលានរៀលនៅឆ្នាំ ២០១៩), ❷. រដ្ឋបាលសារពើពន្ធត្រូវបានពង្រឹងតាមរយៈ នៃការធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាពត៌មាន (E-Filling និង E-Payment), ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្វ័យប្រវត្តិពីអង្គភាពផ្ទៃក្នុង, ការអភិវឌ្ឍនិងគ្រប់គ្រងធនធានមនុស្ស, ការអនុវត្តវិធានការតឹងទារ និងប្រមូលបំណុលពន្ធ, ❸. ការលើកកម្ពស់វប្បធម៌បង់ពន្ធនិងការគោរពច្បាប់, ❹. ការពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ, ❺. ការចូលរួមចំណែកកែលម្អបរិយាកាសវិនិយោគ និងការអភិវឌ្ឍវិស័យឯកជន, និង ❻. ការកែលម្អក្របខណ្ឌគោលនយោបាយសារពើពន្ធ តាមរយៈការកែសម្រួល និងបំពេញបន្ថែមនូវបទបញ្ញត្តិនានាស្តីពីពន្ធដារ។ល។

ទោះជាយ៉ាងណាក៏ដោយ ទន្ទឹមនឹងវឌ្ឍនភាពដែលទទួលបានដូចរៀបរាប់ខាងលើ ក៏នៅមានបញ្ហាប្រឈម និង ចំណុចខ្វះខាតមួយចំនួនដែលទាមទារឱ្យមានការការគិតគូរបន្ថែមទៀតដើម្បីជំរុញឱ្យវិស័យពន្ធដារកម្ពុជា មានភាពល្អប្រសើរ ប្រដំ-ប្រសងទៅនឹងវិស័យពន្ធដារនៅតាមបណ្តាប្រទេសក្នុងតំបន់ និងនៅសកលលោក។ ក្នុងន័យនេះ ក្នុងគោលបំណងសិក្សា និងវាយតម្លៃពីប្រសិទ្ធភាពចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធរបស់កម្ពុជា ឱ្យមានភាពគ្រប់ជ្រុងជ្រោយ ប្រកបដោយភាពច្បាស់លាស់ត្រឹមត្រូវ និងអាចទុកចិត្តបាន, "ឧបករណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធ Tax Administration Diagnostic Assessment Tool-TADAT" ត្រូវបានជ្រើសរើសយកមកពិនិត្យ និងវាយតម្លៃដើម្បីកំណត់ថា

*វិធីសាស្ត្រនេះ ធ្វើការវាយតម្លៃប្រសិទ្ធភាពការងាររបស់រដ្ឋបាលសារពើពន្ធ និងគោលនយោបាយសារពើពន្ធកម្ពុជាមានដូចជា ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលពន្ធ, ការគ្រប់ គ្រងការចុះបញ្ជីអ្នកជាប់ពន្ធ, ការគ្រប់គ្រងហានិភ័យ, ការលើកកម្ពស់វប្បធម៌បង់ពន្ធនិងការគោរពច្បាប់របស់អ្នកជាប់ពន្ធ, ប្រសិទ្ធភាពនៃការផ្តល់សេវាជូនអ្នកជាប់ពន្ធ, ប្រសិទ្ធភាពនៃការបំពេញឯកសារប្រកាសពន្ធនិងការបង់ពន្ធ, ការគ្រប់គ្រងបំណុលពន្ធនិងការដោះស្រាយវិវាទសារពើពន្ធ។ល។*

តើមានភាពសមស្របក្នុងការប្រើប្រាស់សម្រាប់បរិបទជាក់ស្តែងរបស់កម្ពុជា ។ ក្រុមការងារមួយដែលមានសមាសភាព



*ប្រភព÷ និមិត្តសញ្ញា TADAT ក្រោមការចុះបញ្ជីរបស់សហរដ្ឋអាមេរិច*

មកពីអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានជ្រើសរើសវិធីសាស្ត្រ ឧបករណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធ TADAT មកប្រើប្រាស់ ។

ឧបករណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធ (TADAT) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១១ ដោយមូលនិធិរូបិយវត្ថុ អន្តរជាតិ (IMF) បន្ទាប់ពីទទួលបានបទពិសោធន៍ និងភាពជោគជ័យនៃការដាក់ឱ្យអនុវត្តនូវឧបករណ៍ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure Financial Accountability- PEFA) ក្នុងឆ្នាំ២០០១។ តាមការពិតទៅ TADAT មានលក្ខណៈស្រដៀងគ្នាទៅនឹង PEFA ដែរ, គ្រាន់តែ PEFA ត្រូវបានយកមកប្រើប្រាស់សម្រាប់វាយតម្លៃពីប្រសិទ្ធភាព នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) របស់ប្រទេសទាំងមូល។ វាមានវិសាលភាពគ្របដណ្តប់គ្រប់សមាសធាតុទាំងអស់ នៃហិរញ្ញវត្ថុសាធារណៈ។ ចំណែកឯ TADAT ត្រូវបានប្រើប្រាស់សម្រាប់តែវាយតម្លៃប្រសិទ្ធភាពការងាររបស់រដ្ឋបាលសារពើពន្ធ តែប៉ុណ្ណោះ (សម្រាប់វាយតម្លៃតែផ្នែកពន្ធដារប៉ុណ្ណោះ ពោលគឺមិនត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃលើផ្នែកពន្ធគយទេ)។ ប្រភេទចំណូលពន្ធមួយចំនួនដែល TADAT ផ្តោតជាសំខាន់ក្នុងការវាយតម្លៃ រួមមានដូចជា÷ ពន្ធលើប្រាក់ចំណូលសាជីវកម្ម (Corporate Income Tax) ពន្ធលើប្រាក់ចំណូលបុគ្គល (Personal Income Tax) ពន្ធលើតម្លៃបន្ថែម (Value Added Tax) និងការកាត់ទុកពន្ធទៅតាមសមាមាត្រ នៃចំណូលសរុបរបស់បុគ្គល (Pay As You Earn) ។ល។ លទ្ធផល នៃការវាយតម្លៃដោយប្រើប្រាស់ TADAT នឹងអាចឱ្យយើងកំណត់បានពីចំណុចខ្លាំង និងចំណុចខ្សោយ នៃប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការលើកឡើងជាវិធានការ និងផែនការសកម្មភាពសម្រាប់កែលម្អចំណុចខ្វះខាត។

ដោយផ្អែកទៅលើសៀវភៅណែនាំស្តីពីការវាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ TADAT (Field Guide) ខែមេសា ឆ្នាំ ២០១៩ ការវាយតម្លៃជារួមត្រូវផ្អែកទៅលើ លទ្ធផលសមិទ្ធកម្មគន្លឹះ (Performance Outcome Areas - POA) ចំនួន ០៩ ដែល POA នីមួយៗ ត្រូវមានសូចនាករកម្រិតខ្ពស់ (High-Level Indicators) ពី ០២ ទៅ ០៥ (សរុបទាំងអស់មានសូចនាករចំនួន ៣២) ដូចខាងក្រោម÷

**POA 1: ភាពត្រឹមត្រូវនៃការចុះបញ្ជីអ្នកជាប់ពន្ធ (Integrity of the registered taxpayer base)**

- P1-1. ព័ត៌មានអំពីអ្នកជាប់ពន្ធមានភាពត្រឹមត្រូវ និងជឿទុកចិត្តបាន
- P1-2. យល់ដឹងនិងស្គាល់ច្បាស់ពីអ្នកជាប់ពន្ធដែលមានសក្តានុពល

**POA2: ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព (Effective risk management)**

- P2-3. ការកំណត់អត្តសញ្ញាណ, ការវាយតម្លៃ, ចំណាត់ថ្នាក់ និងទំហំ នៃហានិភ័យនៃការអនុវត្ត
- P2-4. ការកាត់បន្ថយហានិភ័យតាមរយៈរៀបចំឱ្យមានផែនការកែលម្អ
- P2-5. តាមដាន និងវាយតម្លៃសកម្មភាពកាត់បន្ថយហានិភ័យនៃការអនុវត្ត
- P2-6. ការគ្រប់គ្រងហានិភ័យផ្នែកប្រតិបត្តិការ
- P2-7. ការគ្រប់គ្រងហានិភ័យផ្នែកធនធានមនុស្ស

**POA 3: អ្នកជាប់ពន្ធគាំទ្រនិងចូលរួមអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ (Supporting voluntary compliance)**

- P3-8. វិសាលភាព, បច្ចុប្បន្នភាពនៃបទប្បញ្ញត្តិ និងការទទួលបានព័ត៌មាន
- P3-9. រយៈពេលនៃការឆ្លើយតបទៅសំណើសុំផ្តល់ព័ត៌មាន
- P3-10. វិសាលភាពនៃបទប្បញ្ញត្តិថ្មីៗ ដើម្បីកាត់បន្ថយចំណាយរបស់អ្នកជាប់ពន្ធ
- P3-11. ទទួលបានមតិយោបល់ត្រឡប់របស់អ្នកជាប់ពន្ធពីសេវាកម្មពន្ធដារ

**POA 4: ការបំពេញឯកសារប្រកាសពន្ធទាន់ពេលវេលា (Timely filing of tax declaration)**

- P4-12. អត្រានៃការបំពេញឯកសារទាន់ពេលវេលា
- P4-13. ការគ្រប់គ្រងអ្នកដែលមិនបានបំពេញឯកសារពន្ធដារ
- P4-14. ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិចដើម្បីបំពេញឯកសារ

**POA 5: ការបង់ពន្ធទាន់ពេលវេលា (Timely payment of tax)**

- P5-15. ប្រើប្រាស់វិធីសាស្ត្របង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិច
- P5-16. ប្រើប្រាស់ប្រព័ន្ធប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព
- P5-17. ការបង់ពន្ធទាន់ពេលវេលា
- P5-18. សន្និធិ និងលំហូរនៃបំណុលពន្ធ

**POA 6: ការរៀបចំឯកសារត្រឹមត្រូវ សម្រាប់ប្រកាសពន្ធ (Accurate reporting in declaration)**

- P6-19. សកម្មភាពការងារដែលត្រូវប្រកាន់យកដើម្បីពិនិត្យ និងទប់ស្កាត់កុំឱ្យមានរបាយការណ៍មិនត្រឹមត្រូវ
- P6-20. ការប្រើប្រាស់ប្រព័ន្ធផ្ទៀងផ្ទាត់ទិន្នន័យដើម្បីស្វែងរករបាយការណ៍ដែលមិនត្រឹមត្រូវ
- P6-21. ការបង្កើតគំនិតផ្តួចផ្តើម ដើម្បីជំរុញអោយរៀបចំរបាយការណ៍បានត្រឹមត្រូវ
- P6-22. ត្រួតពិនិត្យតាមដាន និងវាយតម្លៃកម្រិតនៃភាពមិនត្រឹមត្រូវក្នុងការរៀបចំរបាយការណ៍

**POA 7: ការដោះស្រាយវិវាទសារពើពន្ធប្រកបដោយប្រសិទ្ធភាព (Effective tax dispute resolution)**

- P7-23. កិច្ចដំណើរការដោះស្រាយវិវាទដែលមានលក្ខណៈឯករាជ្យ
- P7-24. រយៈពេលដែលត្រូវប្រើប្រាស់សម្រាប់ដោះស្រាយវិវាទ
- P7-25. វិធានការដែលត្រូវប្រកាន់យក ដោយផ្អែកលើលទ្ធផល នៃការដោះស្រាយវិវាទ

**POA 8: ការគ្រប់គ្រងចំណូលប្រកបដោយស័ក្តិសិទ្ធភាព (Efficient revenue management)**

- P8-26. ការចូលរួមនៅក្នុងដំណើរការព្យាករណ៍ចំណូលពន្ធ
- P8-27. ភាពគ្រប់ជ្រុងជ្រោយនៃប្រព័ន្ធគណនេយ្យចំណូលពន្ធ
- P8-28. ភាពគ្រប់ជ្រុងជ្រោយនៃដំណើរការបង្វិលសងប្រាក់ពន្ធ

**POA 9: គណនេយ្យភាពនិងតម្លាភាព (Accountability and transparency)**

- P9-29. យន្តការត្រួតពិនិត្យផ្ទៃក្នុង
- P9-30. ការត្រួតពិនិត្យផ្ទៃក្រៅទៅលើរដ្ឋបាលសារពើពន្ធ
- P9-31. ការយល់ដឹងជាសាធារណៈទៅលើរដ្ឋបាលសារពើពន្ធ
- P9-32. ការផ្សព្វផ្សាយពីសកម្មភាព, លទ្ធផល និងផែនការ

ជារួម, ផ្អែកលើលទ្ធផល នៃការសិក្សាវាយតម្លៃ ក្រុមការងារមួយដែលមានសមាសភាពមកពីអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់យកវិធីសាស្ត្រវាយតម្លៃ TADAT ក្នុងការត្រួតពិនិត្យលទ្ធផលសមិទ្ធកម្មជាប្រចាំ, ការរាយការណ៍ និងក្របខណ្ឌគណនេយ្យភាព ដោយហេតុថា÷ វិធីសាស្ត្រនេះ ធ្វើការវាយតម្លៃប្រសិទ្ធភាពការងារ របស់រដ្ឋបាលសារពើពន្ធ និងគោលនយោបាយសារពើពន្ធកម្ពុជាមានដូចជា ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលពន្ធ, ការគ្រប់គ្រងការចុះបញ្ជីអ្នកជាប់ពន្ធ, ការគ្រប់គ្រងហានិភ័យ, ការលើកកម្ពស់វប្បធម៌បង់ពន្ធ និង ការគោរពច្បាប់របស់អ្នកជាប់ពន្ធ, ប្រសិទ្ធភាពនៃការផ្តល់សេវាជូនអ្នកជាប់ពន្ធ, ប្រសិទ្ធភាពនៃការបំពេញឯកសារប្រកាសពន្ធ និងការបង់ពន្ធ, ការគ្រប់គ្រងបំណុលពន្ធ និងការដោះស្រាយវិវាទសារពើពន្ធ ។ល។ ហេតុនេះ វិធីសាស្ត្រវាយតម្លៃ TADAT ត្រូវបានកត់សម្គាល់ ថាមានលក្ខណៈសមស្របសម្រាប់លទ្ធផល នៃការវាយតម្លៃ និង លទ្ធផលសូចនាករសមិទ្ធកម្មគន្លឹះ (POA) នៃកម្មវត្ថុទៅនឹងផែនការសកម្មភាពរដ្ឋបាលសារពើពន្ធ៕■

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធ នៃ អ.គ.ហ.*

*ឧបករណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធ (TADAT) ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១១ ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បន្ទាប់ពីទទួលបានបទពិសោធន៍ និងភាពជោគជ័យ នៃការដាក់ឱ្យអនុវត្តនូវឧបករណ៍ចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure Financial Accountability- PEFA) ក្នុងឆ្នាំ២០០១។*




*សមិទ្ធកម្ម និងសូចនាករ TADAT (TADAT Wagon Wheel)*

# មុខងារសវនកម្មផ្ទៃក្នុង និងសមិទ្ធផលសំខាន់ៗ

*ជាផ្លែផ្កាមួយនៃការកែទម្រង់របស់រាជរដ្ឋាភិបាល អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) ត្រូវបានបង្កើតឡើង ដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ (មាត្រា ១, ៤១, ៤២) និងអនុវត្តការងារតាមអនុក្រឹត្យលេខ៤០ អនក្រ.បក ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមុខងារសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ ។*

អង្គភាពសវនកម្មផ្ទៃក្នុងនៃ កសហវ មានឈ្មោះជា នាយកដ្ឋានសវនកម្មផ្ទៃក្នុងដោយយោងតាមអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងដំឡើងជាអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដោយយោងតាមអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣។

### ❖ និយមន័យ និងមុខងារសវនកម្មផ្ទៃក្នុង

➢ **និយមន័យ** ÷ សវនកម្មផ្ទៃក្នុង គឺជាសកម្មភាពពិគ្រោះយោបល់ និងការអះអាងដោយឯករាជ្យ មិនលម្អៀង ដែលរៀបចំឡើង ដើម្បីផ្តល់តម្លៃបន្ថែម និងកែលម្អប្រតិបត្តិការរបស់អង្គភាព។ វាជួយឱ្យអង្គភាពសម្រេចបាននូវគោលបំណងរបស់ខ្លួន ដោយប្រកាន់យកនូវអភិក្រមជាប្រព័ន្ធ មានជំនាញត្រឹមត្រូវ ដើម្បីវាយតម្លៃ និងកែលម្អប្រសិទ្ធភាព **នៃការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងផ្ទៃក្នុង និងដំណើរការអភិបាលកិច្ច។**

➢ **មុខងារ** ÷ មុខងារសំខាន់នៃសវនកម្មផ្ទៃក្នុង គឺវាយតម្លៃដោយឯករាជ្យនូវភាពសមស្របនិងគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលកំពុងមាន និងកំពុងដំណើរការទៅតាមគោលបំណងរបស់អង្គភាព ដើម្បីរួមចំណែកសម្រេចបានប្រកបដោយជោគជ័យតាមគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ❖ ក្របខណ្ឌច្បាប់សវនកម្មផ្ទៃក្នុង

ក្របខណ្ឌច្បាប់សំខាន់ៗ÷

- ❑. ច្បាប់ស្តីពីសវនកម្មលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ "ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង" (មាត្រា ១, ៤១, ៤២)
- ❑. អនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ
- ❑. សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩ ស្តីពីការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈរបស់រាជរដ្ឋាភិបាល
- ❑. សារាចរណែនាំលេខ ១២សរណន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈរបស់រាជរដ្ឋាភិបាល
- ❑. ប្រកាសលេខ ១៥៤៧ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ❑. ប្រកាសលេខ ៧៣៩ សហវ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន។

### ❖ ក្របខណ្ឌជំនាញសវនកម្មផ្ទៃក្នុង

ក្របខណ្ឌជំនាញបច្ចេកទេស÷

- ❑. ក្រមសីលធម៌សម្រាប់សវនករផ្ទៃក្នុង ត្រូវបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ ៤០៥ សហវ.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦
- ❑. ស្តង់ដារវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ត្រូវបានដាក់ ឱ្យប្រើប្រាស់តាមប្រកាសលេខ


ព្រះរាជក្រម
នស/រកម/០៣០០/១០
ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
ព្រះចៅក្រុងកម្ពុជាធិបតី




៤០៥ សហវ.ប្រកចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៦

- ❑. គោលនយោបាយនៃការគ្រប់គ្រងផ្ទៃក្នុង ត្រូវបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ១១០៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៦ និងបានធ្វើបច្ចុប្បន្នភាពតាមប្រកាសលេខ២៩៥ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣


ជំពូកទី ៩
ការបង្កើតសវនកម្មផ្ទៃក្នុង

- ❑. ស្តង់ដាររបាយការណ៍សវនកម្មផ្ទៃក្នុង ត្រូវបានដាក់ឱ្យប្រើតាមសារាចរណែនាំលេខ ០០៣សហវ.អសក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ❑. សៀវភៅណែនាំនីតិវិធីសវនកម្មផ្ទៃក្នុង ត្រូវបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ១៦៧៣សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ❑. គោលនយោបាយ គោលការណ៍ និងស្តង់ដាប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃប្រព័ន្ធ FMIS ដែលបានអនុម័ត និងអនុញ្ញាតដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤
- ❑. ការគ្រប់គ្រងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន ត្រូវបានដាក់ឱ្យប្រើប្រាស់តាមប្រកាសលេខ ១៤៣៦ សហវ.ប្រក ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ❖ សមិទ្ធផលផ្សេងៗ

សមិទ្ធផលសំខាន់ៗ មកទល់បច្ចុប្បន្ន÷

> *សវនកម្មផ្ទៃក្នុង គឺជាសកម្មភាពពិគ្រោះយោបល់ និងការអះអាងដោយឯករាជ្យ មិនលម្អៀង ដែលរៀបចំឡើង ដើម្បីផ្តល់តម្លៃបន្ថែម និងកែលម្អប្រតិបត្តិការរបស់អង្គភាព*

➢ មូលដ្ឋានច្បាប់ និងជំនាញបច្ចេកទេសសវនកម្មផ្ទៃក្នុងមានគ្រប់គ្រាន់ (ដូចចំណុច៣ និង៤) ដើម្បីអនុវត្តស្របតាមនីតិវិធីស្តង់ដារឧត្តមានុវត្តន៍

➢ ក្រសួងស្ថាប័នបានដំណើរការមុខងារសវនកម្មផ្ទៃក្នុង សរុបចំនួន ៤២ (ក្រសួង ២៨ ស្ថាប័ន ៣ និងសហគ្រាស ១១)

➢ រៀងរាល់ឆ្នាំ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួង ស្ថាប័ន ចំនួន ៨ (អនុវត្តពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩) ត្រូវបានត្រួតពិនិត្យប្រសិទ្ធភាពមុខងារសវនកម្មផ្ទៃក្នុង

➢ សិក្ខាសាលាពាក់ព័ន្ធការពង្រឹងសមត្ថភាពសវនករផ្ទៃក្នុងរបស់រាជរដ្ឋាភិបាលសម្រេចបានសរុប ១៤វគ្គ មានសិក្ខាកាមចូលរួមសរុប ១ ៤៥១នាក់

➢ ការបណ្តុះបណ្តាលបន្ថែមទាក់ទងជំនាញសវនកម្មផ្ទៃក្នុង (ទាំងនៅក្នុង កសហវ និងតាមក្រសួង ស្ថាប័ន) សរុប ៥៣ វគ្គ មានសវនករចូលរួម សរុប ២៦២២នាក់

➢ ការបណ្តុះបណ្តាលនានានៅក្រៅប្រទេស ចំនួន១៧លើក មន្ត្រីចូលរួម ចំនួន ៤០នាក់

➢ ការអនុវត្តសវនកម្មតាមអង្គភាពក្រោមឱវាទ កសហវ ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានជាមធ្យមក្នុង ១ ឆ្នាំ មានចំនួន ១០០គោលដៅដោយបានផ្តល់អនុសាសន៍កែលម្អប្រមាណ ៦០០ អនុសាសន៍ ក្នុងនោះប្រព័ន្ធ FMIS ជាគោលដៅ បន្ថែមថ្មី និងកំពុងកសាងសមត្ថភាពធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងលើសមិទ្ធកម្ម៕■

*រៀបចំដោយ÷ ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង*

# ច្បាប់រៀបចំអង្គការ ÷ កសាងទស្សនាទាន ឆ្ពោះទៅពង្រឹងប្រព័ន្ធ

*ជនទុជនជាទូទៅ តែងតែដឹងឮតៗគ្នាថាកាលណាគេនិយាយពីច្បាប់ គឺគេនិយាយពីការចាប់បង្ខំឱ្យអនុវត្ត ទោះបុគ្គលពាក់ព័ន្ធឬប្រជាពលរដ្ឋ ពេញចិត្តឬមិនពេញចិត្ត។ នេះគឺជានិយមន័យដែលត្រូវបានដឹងលឺយ៉ាងទូលំទូលាយដោយសាធារណជន។*

ក្នុងន័យទូលាយនេះ ច្បាប់មានច្រើនប្រភេទ មានឈ្មោះច្រើនយ៉ាង និងមានតម្លៃគតិយុត្តខ្ពស់ទាបមិនដូចគ្នា អាស្រ័យទៅតាមប្រពៃណីនៃប្រព័ន្ធច្បាប់ក្នុងសង្គមនីមួយៗ ។ ទោះយ៉ាងណា ជាសកល គេសង្កេតឃើញថា ប្រទេសទាំងអស់តែងរៀបចំប្រព័ន្ធច្បាប់របស់ខ្លួន ទៅតាមលំដាប់មួយ ដែលគេប្រសិទ្ធនាមថា "គោលការណ៍ឋានានុក្រមនៃបទដ្ឋានគតិយុត្ត" (Hierarchy of Norms)* ។ តាមទ្រឹស្តីខាងលើ គេប្រដូចឋានានុក្រម នៃលិខិតបទដ្ឋានគតិយុត្ត ទៅនឹងពីរ៉ាមីតមួយ ដែលមានកំពូលជាផ្នែកខ្ពស់ជាងគេបង្អស់ ផ្នែកកណ្តាល និងផ្នែកបាតដែលទាបជាងគេបង្អស់។

### ក. សញ្ញាណនូទៅនៃច្បាប់រៀបចំអង្គការ

ជាទូទៅ នៅលើកំពូលបង្អស់នៃលិខិតបទដ្ឋាន គឺរដ្ឋធម្មនុញ្ញដែលត្រូវបានចាត់ទុកជាច្បាប់កំពូល បានសេចក្តីថាគ្មានបទដ្ឋានគតិយុត្តណាដែលខ្ពស់ជាងរដ្ឋធម្មនុញ្ញនោះទេ។ គ្រប់លិខិតបទដ្ឋានគតិយុត្ត ត្រូវតែគោរពតាមជាដាច់ខាត និងត្រូវនិរាករចោលបើសិនណាមានខ្លឹមសារផ្ទុយនឹងរដ្ឋធម្មនុញ្ញ។ នៅក្រោមរដ្ឋធម្មនុញ្ញ គឺច្បាប់ (ច្បាប់ក្នុងន័យចង្អៀត ឬ ក្នុងន័យទម្រង់) ដែលសំដៅដល់លិខិតបទដ្ឋានដែលត្រូវអនុម័តដោយអង្គការនីតិប្បញ្ញត្តិ ឬសភា (រដ្ឋសភា ឬ/និងព្រឹទ្ធសភា) ហើយដែលត្រូវប្រកាសឱ្យប្រើដោយប្រមុខរដ្ឋ។ ច្បាប់ដែលអនុម័តដោយសភានេះ មានយ៉ាងតិច ៣ ប្រភេទនិងមានឋានានុក្រមពីខ្ពស់ទៅទាបដូចតទៅ÷ ទី១ ច្បាប់ធម្មនុញ្ញ (Constitutional law), ទី២ ច្បាប់រៀបចំអង្គការ (Organic law) និង ទី៣ ច្បាប់ធម្មតា (Ordinary law)។

**ច្បាប់ធម្មនុញ្ញ** សំដៅដល់ច្បាប់ដែលធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញ។ ដូចនេះ ច្បាប់ធម្មនុញ្ញ មានតម្លៃគតិយុត្តស្មើនឹងរដ្ឋធម្មនុញ្ញដែរ ព្រោះបទប្បញ្ញត្តិទាំងឡាយក្នុងច្បាប់នេះ នឹងត្រូវយកទៅបញ្ចូលដោយកែប្រែ លុបចោល ឬបំពេញបន្ថែមក្នុងរដ្ឋធម្មនុញ្ញតែម្តង។

**ច្បាប់កម្រិតទី២** គឺ *ច្បាប់រៀបចំអង្គការដែលស្ថិតនៅចន្លោះរវាង រដ្ឋធម្មនុញ្ញ និងច្បាប់ធម្មតា។ និយាយម្យ៉ាងទៀត ច្បាប់រៀបចំអង្គការមានតម្លៃគតិយុត្តទាបជាងរដ្ឋធម្មនុញ្ញ ហើយមិនត្រូវមានខ្លឹមសារផ្ទុយនឹងរដ្ឋធម្មនុញ្ញឡើយ តែទន្ទឹមនោះច្បាប់រៀបចំអង្គការមានតម្លៃគតិយុត្តខ្ពស់ជាងច្បាប់ធម្មតា គឺច្បាប់ធម្មតាត្រូវអនុលោមតាម។ ច្បាប់កម្រិតទី៣ គឺច្បាប់ធម្មតាដែលត្រូវបានអនុម័តដោយសភា តាមនីតិវិធីធម្មតា។*

បន្ទាប់មក នៅក្រោមច្បាប់ ឬនិយាយម្យ៉ាងទៀត នៅបាតនៃពីរ៉ាមីត នៃបទដ្ឋានគតិយុត្តតែម្តង គឺ បទដ្ឋានអនុវត្តច្បាប់

*Hierarchy of norms ជាទ្រឹស្តីបង្កើតឡើងដោយលោក Hans Kelsen ជាអ្នកច្បាប់ជនជាតិអូទ្រីស (១៨៨១-១៩៧៣)*






ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*មាត្រាទី ៥៧ នៃច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣ បានកំណត់ថា "ប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់" ដោយមិនបានកំណត់លក្ខណៈសម្បត្តិ "រៀបចំអង្គការ" ឡើយ ។*

(Regulations) ដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្រតិបត្តិ (រាជរដ្ឋាភិបាល)។ នៅប្រទេសកម្ពុជា បទដ្ឋានអនុវត្តទាំងនេះមានច្រើនកម្រិតនិងមានឋានានុក្រមពីខ្ពស់ទៅទាបដូចតទៅ **ទី១) កម្រិតព្រះមហាក្សត្រ÷** ព្រះរាជក្រឹត្យ, **ទី២) កម្រិតនាយករដ្ឋមន្ត្រី÷** អនុក្រឹត្យ, សេចក្តីសម្រេច, បទបញ្ជា និងសារាចររបស់រាជរដ្ឋាភិបាល និង **ទី៣) កម្រិតរដ្ឋមន្ត្រី÷** ប្រកាស, សេចក្តីសម្រេចរបស់ក្រសួង និងសារាចររបស់ក្រសួង។

ដោយឡែក សម្រាប់ច្បាប់រៀបចំអង្គការ និយមន័យ និងតម្លៃរបស់វានៅក្នុងការអនុវត្តនៅមានភាពស្រពិចស្រពិលនៅឡើយ។ គេអាចសាកល្បងកំណត់ ដោយផ្អែកលើទ្រឹស្តីថា ច្បាប់រៀបចំអង្គការ ជាច្បាប់ដែលពាក់ព័ន្ធនឹងការបង្កើត ឬរៀបចំស្ថាប័នសាធារណៈ (អំណាចសាធារណៈ)។ ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជារដ្ឋធម្មនុញ្ញ នៃប្រទេសមួយចំនួនផ្សេងទៀតជាទូទៅ មិនបានផ្តល់និយមន័យឱ្យចំៗលើច្បាប់រៀបចំអង្គការឡើយ តែច្បាប់កំពូលទាំងនេះ តែងតែមិនខកខានឡើយក្នុងការបរិយាយពាក់ព័ន្ធនឹងនីតិវិធីនៃការអនុម័ត និងវិសោធនកម្មច្បាប់ប្រភេទនេះ ដែលមានលក្ខណៈពិសេសខុសពីនីតិវិធី នៃការអនុម័តច្បាប់ធម្មតា។

ចំណោទបញ្ហា ស្ថិតនៅត្រង់ថា តើគេអាចផ្តល់លក្ខណៈសម្បត្តិឱ្យច្បាប់មួយជាច្បាប់រៀបចំអង្គការ បានយ៉ាងដូចម្តេច។

## ខ. ឧត្តមានុភាពអន្តរជាតិ ÷ ករណីច្បាប់រៀបចំអង្គការក្នុងប្រព័ន្ធច្បាប់បារាំង

ប្រព័ន្ធរដ្ឋបាលសាធារណៈខ្មែរ ជាពិសេសប្រព័ន្ធច្បាប់ខ្មែរ ទទួលឥទ្ធិពលយ៉ាងសន្ធឹកសន្ធាប់ពីបារាំង តាំងពីសម័យអាណាព្យាបាលមកដល់បច្ចុប្បន្ន។ ដូចនេះ បទពិសោធន៍នៃការអនុវត្តច្បាប់រៀបចំអង្គការក្នុងប្រព័ន្ធច្បាប់បារាំង គឺជាករណីដ៏ស័ក្តិសមបំផុតសម្រាប់ការសិក្សា។

រដ្ឋធម្មនុញ្ញបារាំងឆ្នាំ១៩៥៨ បានលើកឡើងនៅក្នុងមាត្រាផ្សេងៗពីគ្នា នូវកម្មវត្ថុ ឬ វិស័យដែលត្រូវចែងកំណត់ដោយច្បាប់រៀបចំអង្គការ។ ជាឧទាហរណ៍ មាត្រា៦ នៃរដ្ឋធម្មនុញ្ញបារាំង បានបញ្ញត្តថា "*វិធានអនុវត្ត នៃការបោះឆ្នោតជ្រើសតាំងប្រធានាធិបតី <u>ត្រូវកំណត់ដោយច្បាប់រៀបចំអង្គការ</u>*", ឧទាហរណ៍ទី២ មាត្រា២៥ ចែងថា "*<u>ច្បាប់រៀបចំអង្គការ</u>កំណត់នូវអាណត្តិសភា ចំនួនសមាជិក អភ័យឯកសិទ្ធិ លក្ខខណ្ឌជាប់ឆ្នោត និងវិសមិតភាព*" និងជាពិសេស ឧទាហរណ៍ទី ៣ មាត្រា៣៤ កំណត់ថា "*ច្បាប់ថវិកាកំណត់ធនធាននិងបន្ទុករបស់រដ្ឋនៅក្នុងលក្ខខណ្ឌ និង<u>ការកំណត់ដោយច្បាប់អង្គការ</u>*"។ ក្រៅពីនេះ មានករណីជាច្រើនទៀតដែលរដ្ឋធម្មនុញ្ញបារាំងតម្រូវ ហើយច្បាប់រៀបចំអង្គការដែលមានសម្បូរច្រើនជាងគេ គឺ ច្បាប់ដែលពាក់ព័ន្ធនឹងលក្ខន្តិកៈសមាជិកសភា, ច្បាប់ពាក់ព័ន្ធនឹងការបោះឆ្នោត និងច្បាប់ពាក់ព័ន្ធនឹងវិសមិតភាព។ ដើម្បីធានានូវភាពច្បាស់លាស់ និងចៀសវាងចំណោទបញ្ហាជាមួយនឹងច្បាប់ធម្មតា ក្រុមប្រឹក្សាធម្មនុញ្ញបារាំងបានសម្រេចថា រាល់សេចក្តីព្រាងច្បាប់រៀបចំអង្គកា ត្រូវតែបញ្ជាក់លក្ខណៈ "រៀបចំអង្គការ" នៅក្នុងឈ្មោះ នៃច្បាប់នោះតែម្តង។

ជានីតិវិធីអនុម័ត ច្បាប់រៀបចំអង្គការត្រូវអនុម័តដោយរដ្ឋសភាបារាំង តាមនីតិវិធីពិសេសមួយដោយឡែកពីការអនុម័តច្បាប់ធម្មតា។ ក្នុងន័យនេះ មានលក្ខខណ្ឌនីតិវិធីចំនួន៤ យ៉ាងតិចដែលមានដូចជា÷ ទី១) សេចក្តីព្រាងច្បាប់រៀបចំអង្គការ អាចនឹងយកមកពិចារណាពិភាក្សាបានតែក្នុងរយៈពេលយ៉ាងតិច ១៥ ថ្ងៃ ក្រោយការផ្ញើជូនរដ្ឋសភាតែប៉ុណ្ណោះ, ទី២) រដ្ឋសភា ត្រូវអនុម័តច្បាប់រៀបចំអង្គការដោយមតិភាគច្រើនដាច់ខាត ខណៈដែលការអនុម័តសម្រាប់ច្បាប់ធម្មតា ទាមទារសម្លេងមតិភាគច្រើនដោយប្រៀបធម្មតាតែប៉ុណ្ណោះ, ទី៣) ការអនុម័តយល់ព្រមពីព្រឹទ្ធសភាមានភាពចាំបាច់ ក៏ប៉ុន្តែ ក្នុងករណីដែលព្រឹទ្ធសភាបោះឆ្នោតមិនយល់ព្រម ច្បាប់រៀបចំអង្គការនឹងត្រូវបញ្ជូន មករដ្ឋសភាវិញ ហើយអាចអនុម័តដោយរដ្ឋសភា ជាលើកទី ២ បាន លុះត្រាតែទទួលបានសម្លេងឯកភាព តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងអស់ និងចុងក្រោយ ទី៤) ការត្រួតពិនិត្យធម្មនុញ្ញភាពលើច្បាប់រៀបចំអង្គការ ដោយក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវតែធ្វើជាកាតព្វកិច្ច មុនការប្រកាសឱ្យប្រើច្បាប់នេះ។




## គ. ធាតុចូលសម្រាប់ប្រព័ន្ធច្បាប់ និងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា

*តេអាចចោទជាសំណួរថា តើគេអាចរៀបចំច្បាប់រៀបចំអង្គការសម្រាប់វិស័យ ឬកម្មវត្ថុផ្សេង ដែលមិនត្រូវបាន តម្រូវនៅក្នុងរដ្ឋធម្មនុញ្ញដែរឬទេ ដូចជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជាដើម។ ការបកស្រាយទៅនឹងសំណួរនេះ គឺជាសមត្ថកិច្ចធម្មនុញ្ញ និងផ្តាច់មុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។*

### គ.១. ច្បាប់រៀបចំអង្គការនៅកម្ពុជា

បើសង្កេតទៅលើរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ឃើញថាមានករណីចំនួន ៣ ដែលត្រូវបានកំណត់ឱ្យរៀបចំជាច្បាប់ រៀបចំអង្គការដែលមានដូចតទៅ÷ ការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម (មាត្រា ១៣៤ ថ្មី), ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ (មាត្រា ១៤៤ ថ្មី) និងការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (មាត្រា ១៤៦ ថ្មី)។ ជាលទ្ធផលផ្អែកលើបទប្បញ្ញត្តិរដ្ឋធម្មនុញ្ញទាំង៣ មាត្រា នេះ, ច្បាប់រៀបចំអង្គការចំនួន ៤ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដែលរួមមាន ១) ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ២) ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ, ៣) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ៤) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ-សង្កាត់។ ទោះបីច្បាប់ទាំងនេះ មិនបានបញ្ជាក់ដោយខ្លួនឯង នៅក្នុងបទប្បញ្ញត្តិរបស់ខ្លួន ថាជាច្បាប់អង្គការក៏ដោយ វាមានតម្លៃជាច្បាប់ រៀបចំអង្គការដោយស្វ័យប្រវត្តិ ដោយសំអាងលើបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញដូចមានបញ្ជាក់ខាងលើស្រាប់។ ដូចនេះ ក្នុងករណីមានវិវាទខ្លឹមសារបញ្ញត្តិជាមួយនឹងច្បាប់ធម្មតា ច្បាប់រៀបចំអង្គការទាំង ៤ ខាងលើត្រូវមានឧត្តមានុភាព។

បើយើងក្រឡេកទៅមើលនីតិវិធី នៃការអនុម័តច្បាប់រៀបចំអង្គការ, មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជា បាន កំណត់ថា "បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងប្រកាសឱ្យប្រើ"។ ត្រង់នេះ ចោទជាសំណួរសម្រាប់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ថាតើជាច្បាប់រៀបចំអង្គការដែរឬទេ? រដ្ឋធម្មនុញ្ញមិនបានបញ្ជាក់ថាបទបញ្ជាផ្ទៃក្នុងទាំងនេះ ត្រូវដាក់ឱ្យប្រើដោយច្បាប់រៀបចំអង្គការឡើយ ក៏ប៉ុន្តែបានតម្រូវឱ្យត្រួតពិនិត្យដោយក្រុមប្រឹក្សាធម្មនុញ្ញមុនប្រកាសឱ្យប្រើ ដូចគ្នានឹងច្បាប់រៀបចំអង្គការដែរ។

គេអាចចោទជាសំណួរថា តើគេអាចរៀបចំច្បាប់រៀបចំអង្គការសម្រាប់ វិស័យ ឬ កម្មវត្ថុផ្សេងដែលមិនត្រូវបាន តម្រូវនៅក្នុងរដ្ឋធម្មនុញ្ញដែរឬទេ ដូចជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជាដើម។ ការបកស្រាយទៅនឹងសំណួរនេះ គឺជាសមត្ថកិច្ចធម្មនុញ្ញ និងផ្តាច់មុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

### គ.២. ករណីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

នៅកម្ពុជា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ អាចចាត់ទុកជាច្បាប់មេមួយ ព្រោះមានវិសាលភាពគ្រប ដណ្តប់លើគ្រប់ក្រសួង-ស្ថាប័ន និងរាល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការរៀបចំ ការគ្រប់គ្រង ចាត់ចែង និងការអនុវត្តថវិកាជាតិ។ បើពិនិត្យលើការអនុវត្តជាក់ស្តែង ច្បាប់នេះ មានចរឹតជាច្បាប់រៀបចំអង្គការមួយដែរ ដោយហេតុថាមានច្បាប់ជាច្រើន ជាពិសេស ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំត្រូវបានរៀបចំឡើងដោយអនុលោមតាមបទប្បញ្ញត្តិ នៃច្បាប់នេះ។ ហេតុនេះហើយ ទើបនៅប្រទេសបារាំងច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានកំណត់ថាជាច្បាប់រៀបចំអង្គការ (Loi organique relative aux lois de finances)។

ចំពោះបែបនេះ មាត្រា ៥៧ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៩៣ បានកំណត់ថា "**ប្រព័ន្ធហិរញ្ញវត្ថុ ត្រូវកំណត់ក្នុងច្បាប់**" ដោយមិនបានកំណត់លក្ខណៈសម្បត្តិ "រៀបចំអង្គការ" ឡើយ។ ទំនងដោយសារមូលហេតុនេះ ទើបច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្នាំ ២០០៨ បានបញ្ញត្តបញ្ជាក់ជាការបំពេញបន្ថែមថា "ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើមានបទប្បញ្ញត្តិ នៃច្បាប់ផ្សេងទៀតមិនស្របគ្នានឹងបទប្បញ្ញត្តិទាំងឡាយ នៃច្បាប់នេះ"។ បទប្បញ្ញត្តិនេះហាក់មានអត្ថន័យបញ្ជាក់ត្រង់ៗថាច្បាប់នេះមានតម្លៃខ្ពស់ជាងច្បាប់ធម្មតា ហើយការរៀបចំសេចក្តីព្រាងច្បាប់ទាំងឡាយ ត្រូវតែយកច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មកពិនិត្យអនុលោមតាម។ បើមានតម្លៃខ្ពស់ជាងច្បាប់ធម្មតា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ គួរតែមានតម្លៃជាច្បាប់រៀបចំអង្គការ។ ទោះយ៉ាងណាដូចបានលើកឡើងខាងលើរួចមកហើយថា ការបំភ្លឺនេះគឺជាតួនាទីផ្តាច់មុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។ ករណីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈខាងលើ អាចចាត់ទុកថាជាយុទ្ធសាស្ត្រច្បាប់មួយ ក្នុងការតម្លើងតម្លៃច្បាប់មួយ ឱ្យខ្ពស់ជាងច្បាប់ធម្មតាផ្សេងទៀត។ ក្រៅពីនេះ គេក៏អាចពង្រឹងឋានៈគតិយុត្តក្រៅផ្លូវការទៅឱ្យច្បាប់មួយផងដែរ តាមរយៈការប្រើប្រាស់នីតិវិធី ដូចមានកំណត់ក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ នោះគឺ ការស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យសេចក្តីព្រាងច្បាប់មុនប្រកាសឱ្យប្រើ បើទោះបីរដ្ឋធម្មនុញ្ញមិនបានតម្រូវជាកាតព្វកិច្ចក៏ដោយ។ គួរបញ្ជាក់ថា ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបានអនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើបានក្រៅពីបទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយដែលត្រូវបញ្ជូនឱ្យទៅពិនិត្យជាកាតព្វកិច្ច។

សរុបមក សញ្ញាណ នៃច្បាប់រៀបចំអង្គការនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា នៅមានភាពស្រពិចស្រពិលនៅឡើយ ដែលករណីនេះ អាចជាការដ្ឋានកែទម្រង់ដ៏មានសារៈសំខាន់មួយនៅក្នុងក្របខណ្ឌ នៃកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលកម្ពុជា។ ទន្ទឹមនេះ លទ្ធភាពធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ក៏ជាចំណុចមួយដែលគួរពិចារណាផងដែរ ដើម្បីកសាងទស្សនាទានធម្មនុញ្ញកម្ពុជាឱ្យកាន់តែរឹងមាំ ដែលជាវិភាគទានដ៏មានសារៈសំខាន់សម្រាប់ ពង្រឹងក្របខណ្ឌគតិយុត្តនៅកម្ពុជាជារួម ក៏ដូចជាក្នុងវិស័យផ្សេងៗជាពិសេសវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៕■

*រៀបចំដោយ÷ ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ អ.គ.ហ.*

# ផ្នែកទី ៣

# សុន្ទរកថា



# សុន្ទរកថា ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS

## *ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ជាផ្លូវការ សណ្ឋាគារឡឺរ៉ូយ៉ាល់ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០២០ ។*

*-ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន*
*-លោកស្រី Camilla Lombard តំណាងសហភាពអឺរ៉ុប និងដៃគូអភិវឌ្ឍ, លោក លោកស្រី តំណាងដៃគូអភិវឌ្ឍ*
*-ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និង ជាសមាជិក នៃក្រុមការងារគ្រប់គ្រង និង ក្រុមការងារអនុវត្តគម្រោង FMIS*
*-អង្គពិធីជាទីមេត្រី !*



ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ថ្លែងសន្ទរកថា នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០

ក្នុងនាមឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងនាមជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ខ្ញុំសូមស្វាគមន៍ និងសូមថ្លែងអំណរគុណ ចំពោះវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ, មន្ត្រីរាជការក្រសួង-ស្ថាប័ន និងតំណាងដៃគូអភិវឌ្ឍន៍ ដែលមានវត្តមានក្នុងពិធីប្រកាស ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា **ព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាផ្លូវការ នៅក្រសួង-ស្ថាប័ន ចំនួន ១៧ និងអង្គភាពថវិកាដែល ជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣** នាពេលនេះ។

អង្គពិធីថ្ងៃនេះ មានគោលបំណងប្រកាសជាផ្លូវការអំពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅក្រសួង-ស្ថាប័នចំនួន ១៧ ចុងក្រោយ រួមទាំងអង្គភាព ថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣ បន្ថែមថ្មី សម្រាប់ឆ្នាំ២០២០ នេះ និងផ្តល់អនុសាសន៍បន្ថែម សម្រាប់កិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការអនុវត្តគម្រោង FMIS និងបន្តចូលរួមចំណែកជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានជោគជ័យ ស្របតាម អនុសាសន៍ប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានចាត់ទុកថា FMIS មានតួនាទីជាឆ្អឹងខ្នង ក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ស្ថិតក្នុងដំណាក់កាលទី ២ គឺ "គណនេយ្យភាពហិរញ្ញវត្ថុ" និងដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" នៃកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រព័ន្ធ FMIS បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមចំណែកពង្រឹងគណនេយ្យភាព, តម្លាភាព និងគាំទ្រដល់ការគ្រប់គ្រង និងតាមដានការអនុវត្តថវិកា និង ហិរញ្ញវត្ថុ របស់ក្រសួង-ស្ថាប័ន ស្របពេលជាមួយនឹងការអនុវត្តថវិកាកម្មវិធី និងជាពិសេសគាំទ្រដល់ដំណើរ ឈានឆ្ពោះទៅដំណាក់កាលទី ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាគឺ "***គណនេយ្យភាពសមិទ្ធកម្ម***" នៅឆ្នាំ២០២១ ខាងមុខនេះ។


ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍន៍ ចូលរួមក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS នៅថ្ងៃទី២៤ កុម្ភៈ ឆ្នាំ២០២០

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបអង្គពិធីអំពីវឌ្ឍនភាពសង្ខេប នៃការអនុវត្តគម្រោង FMIS ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៩ ដូចតទៅ÷ ក្នុងឆ្នាំ ២០១៦, ប្រព័ន្ធ FMIS បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅអគ្គនាយកដ្ឋាន គន្លឹះៗ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំង រតនាគាររាជធានី-ខេត្តទាំង ២៥ នៅក្នុងការអនុវត្តគម្រោង FMIS **ជំហានទី ១**។ ក្នុង **ជំហានទី ២**, គិតត្រឹម ឆ្នាំ ២០១៩ នេះ, ប្រព័ន្ធ FMIS បានដាក់ឱ្យប្រើប្រាស់នៅក្រសួង-ស្ថាប័នចំនួន ២០ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១២ រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥។

ទន្ទឹមនេះ, ប្រព័ន្ធ FMIS ក៏បានដាក់ឱ្យដំណើរការនូវប្រព័ន្ធទូទាត់ អេឡិកត្រូនិក (Electronic Fund Transfer) ជាមួយធនាគារជាតិនៃកម្ពុជា រួមទាំងការធ្វើសន្ទានកម្មផ្លាស់ប្តូរទិន្នន័យដោយស្វ័យប្រវត្តិ ជាមួយប្រព័ន្ធជា ច្រើនទៀត ដូចជា ១-ប្រព័ន្ធធនាគាររបស់ធនាគារជាតិនៃកម្ពុជា, ២-ប្រព័ន្ធធនាគាររបស់ធនាគារពាណិជ្ជដៃគូ រួមមាន ធនាគារអេស៊ីលីដា, ធនាគារកាណាឌីយ៉ា, ធនាគារកម្ពុជាសាធារណៈ, ធនាគារវឌ្ឍនៈ និងធនាគារជេត្រាស់, ៣-ប្រព័ន្ធគ្រប់គ្រងចំណូលពន្ធគយ និងរដ្ឋាករ (ASYCUDA និង E-Customs) របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង ៤-ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ (DMFAS) របស់អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល ។

### *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ថ្ងៃនេះ, ប្រព័ន្ធ FMIS បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅក្រសួង-ស្ថាប័ន ចំនួន ១៧ ចុងក្រោយ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣ បន្ថែមថ្មី ដោយប្រើប្រាស់មុខងារស្នូលចំនួន ៤ រួមមាន **ទី១. មុខងារវិភាជន៍ថវិកា, ទី២. មុខងារទិញ និងធានាចំណាយ, ទី៣. មុខងារគណនីត្រូវសង និងចំណាយថវិកា** និង**ទី៤. មុខងារគណនីត្រូវទារ និងចំណូលថវិកា**។ ក្រសួង-ស្ថាប័នទាំង ១៧ រួមមាន÷ ក្រសួងព្រះបរមរាជវាំង, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា, ក្រសួងការពារជាតិ, ក្រសួងមហាផ្ទៃ (ទាំងផ្នែកសន្តិសុខសាធារណៈ និងផ្នែករដ្ឋបាលទូទៅ), ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច, ក្រសួងរ៉ែ និងថាមពល, ក្រសួងផែនការ, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងធម្មការ និងសាសនា, ក្រសួងយុត្តិធម៌ (រួមទាំង ស្ថាប័នតុលាការ), គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។

នៅដើមឆ្នាំ ២០២០ នេះ, ប្រព័ន្ធ FMIS ក៏បានដាក់ឱ្យដំណើរការនូវ ប្រព័ន្ធសន្ទានកម្មផ្លាស់ប្តូរទិន្នន័យចំណូលថវិកាជាតិ ជាមួយនឹងប្រព័ន្ធគ្រប់គ្រង ចំណូលមិនមែនសារពើពន្ធ (NRMIS) ដែលបានផ្តល់នូវអត្ថប្រយោជន៍មួយចំនួនបន្ថែមទៀត ដូចជា ជំរុញការកាត់បន្ថយនូវឯកសារសលាកបត្របង់ ចំណូលថវិកាជាប្រចាំថ្ងៃ ជំនួសដោយទិន្នន័យអេឡិកត្រូនិក និង ការបូកសរុប ជាប្រចាំខែ, បង្កើននូវស្វ័យប្រវត្តិកម្មទិន្នន័យ និងកាត់បន្ថយនូវការងារ កត់ត្រាចំណូលថវិកាស្ទួនក្នុងប្រព័ន្ធ FMIS ជំនួសដោយការផ្លាស់ប្តូរទិន្នន័យ អេឡិកត្រូនិក និងកាត់បន្ថយនូវពេលវេលាក្នុងការទទួលស្គាល់ចំណូលថវិកាជាតិ ជាដើម។

**លើសពីនេះទៀត, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងធ្វើជាគំរូក្នុងការអនុវត្តនីតិវិធីអនុវត្តការងារតម្រង់ទិសថ្មី ដោយប្រើប្រាស់ប្រព័ន្ធ FMIS ទាំងស្រុង សម្រាប់អនុវត្តនីតិវិធីទូទាត់ចំណាយបៀវត្ស និងទូទាត់ត្រង់ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងឆ្នាំ ២០២០ នេះ និង បន្តរៀបចំនីតិវិធីតម្រង់ទិសផ្សេងៗទៀត ក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុព្រមទាំងបន្តពង្រីកការអនុវត្តនេះ ទៅដល់ ក្រសួង-ស្ថាប័ន ដែលបានប្រើប្រាស់ប្រព័ន្ធ FMIS។**

អង្គពិធីថ្ងៃនេះ គឺជាសក្ខីភាពបញ្ជាក់ច្បាស់អំពីការខិតខំប្រឹងប្រែងរួមគ្នាប្រកបដោយបុរេសកម្មរវាងក្រសួង-ស្ថាប័ន និងក្រុមការងារគ្រប់គ្រងគម្រោង FMIS ដោយបានឆ្លងកាត់ដំណាក់កាលជាច្រើនជាមួយគ្នា រហូតបានប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនៅក្នុងឆ្នាំ ២០២០ នេះ។ វឌ្ឍនភាព និង ជោគជ័យនេះ មិនអាចកើតមានឡើង

ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បាននោះទេ បើសិនជាគ្រប់ភាគីពាក់ព័ន្ធ មិនមានឆន្ទៈសហការ គាំទ្រ និង ការចូលរួមប្រកបដោយបុរេសកម្ម។

ក្នុងនាមជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ខ្ញុំសូមថ្លែង អំណរគុណចំពោះសមិទ្ធផលគួរជាទីមោទនៈទាំងអស់នេះ និងសូមអំពាវនាវឱ្យមានការចូលរួមសហការសាមគ្គីគ្នាបន្ថែមទៀត ពីគ្រប់ភាគីពាក់ព័ន្ធជាមួយក្រុមការងារគ្រប់គ្រងគម្រោង FMIS ដើម្បីសម្រេចឱ្យបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត សម្រាប់ប្រទេសជាតិ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន ទាំង ១៧ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញទាំង ១៣ បន្ថែមថ្មី នឹងប្រើប្រាស់ប្រព័ន្ធ FMIS ជាឧបករណ៍ ដើម្បីទាញប្រយោជន៍ឱ្យបានជាអតិបរមា សម្រាប់ការកត់ត្រា តាមដាន ត្រួតពិនិត្យវិភាគ និងគ្រប់គ្រង ការអនុវត្តថវិកា និង ហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយគណនេយ្យភាព និងតម្លាភាព ក្នុងការបម្រើសេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ទន្ទឹមនេះ, សូមកុំយល់ច្រឡំថា ប្រព័ន្ធ FMIS គឺជារបស់ក្រសួងសេដ្ឋកិច្ច និង-ហិរញ្ញវត្ថុ បម្រើផលប្រយោជន៍ជូនតែក្រសួងមួយនេះ តាមពិតប្រព័ន្ធនេះ គឺជារបស់ប្រជាជាតិកម្ពុជាទាំងមូល និងមានគោលដៅចុងក្រោយបម្រើដល់ការពង្រឹងប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈនានាជូនប្រជាជន និងការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព ដូច្នេះ, ក្រសួង-ស្ថាប័នទាំងអស់ ក៏ជាម្ចាស់របស់ប្រព័ន្ធនេះ សូមប្រើប្រាស់ប្រព័ន្ធនេះ ឱ្យអស់សក្តានុពលដើម្បីគាំទ្រដល់ទាំងការគ្រប់គ្រង តាមដាន និងអនុវត្តថវិកាផង និង ប្រើប្រាស់ដើម្បីជាឧបករណ៍បង្កើនគណនេយ្យភាព និងការគ្រប់គ្រងសមិទ្ធកម្មនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង-ស្ថាប័ននីមួយៗដោយឡែកៗផងដែរ។



ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន ១៧ និងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣ នៅថ្ងៃទី២៤ កុម្ភៈ ឆ្នាំ២០២០

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ខ្ញុំសូមផ្តល់នូវការកត់សម្គាល់ និងជំរុញការលើកទឹកចិត្ត ដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការបន្តសហការអនុវត្តគម្រោង FMIS ដូចតទៅ÷

❶. អគ្គនាយកដ្ឋានគន្លឹះៗ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស អគ្គ-នាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានរតនាគារ-ជាតិ សូមបន្តចូលរួមប្រកបដោយបុរេសកម្មក្នុងការជួយតម្រង់ទិស និងគាំទ្រដល់អ្នកប្រើប្រាស់ប្រព័ន្ធ FMIS ថ្មីៗ និងជួយផ្សព្វ-ផ្សាយ ឱ្យបានទូលំទូលាយនូវការណែនាំនានា ផ្សារភ្ជាប់រវាងការអនុវត្តថវិកា និងការប្រើប្រាស់ប្រព័ន្ធ FMIS ជៀសវាង ឱ្យបានជាអតិបរមា នូវការណែនាំ ដែលមានភាពមិនច្បាស់លាស់នៅក្នុងនីតិវិធី នៃការអនុវត្តថវិកា និងជួយក្នុងការពង្រឹងគណនេយ្យភាពនៃប្រតិបត្តិការហិរញ្ញវត្ថុនានានៅក្នុងប្រព័ន្ធ FMIS។

❷. ក្រសួង-ស្ថាប័នទាំង ១៧ ដែលបានប្រើប្រាស់ប្រព័ន្ធ FMIS នាឆ្នាំនេះ សូមបន្តបង្កើននូវសមត្ថភាពជំនាញ ទាំងជំនាញហិរញ្ញវត្ថុសាធារណៈ និងជំនាញក្នុងការប្រើប្រាស់ប្រព័ន្ធ FMIS ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានភាពជាម្ចាស់ក្នុងការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុរបស់ខ្លួនតាមរយៈ ការប្រើប្រាស់ប្រព័ន្ធ FMIS និងជៀសវាងជាអតិបរមាក្នុងរយៈពេលខ្លីក្នុងការផ្លាស់ប្តូរមន្ត្រីដែលជាអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ដែលមានវិញ្ញាបនបត្រជាអ្នកប្រើប្រាស់ប្រព័ន្ធ FMIS រួច ។

❸. ក្រសួង-ស្ថាប័ន និងអង្គភាពដែលប្រើប្រាស់ប្រព័ន្ធ FMIS ទាំងអស់ សូមធ្វើការត្រួតពិនិត្យនូវមុខងារ និងតួនាទីរបស់មន្ត្រីនីមួយៗ, រចនាសម្ព័ន្ធការងារផ្ទៃក្នុង និងកំណត់នូវកម្រិតហានិភ័យ នៃប្រភេទប្រតិបត្តិការអនុវត្ត ថវិកា និងហិរញ្ញវត្ថុ ជាបណ្តើរៗ ដើម្បីត្រៀមខ្លួនសហការជាមួយក្រុមការងារ គ្រប់គ្រងគម្រោង FMIS ក្នុងការរៀបចំនីតិវិធីតម្រង់ទិសថ្មី ស្របតាមផែនការ តម្រង់ទិសនីតិវិធីអនុវត្តការងារ (Business Processes Streamlining) ដែល បានបង្ហាញកាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ២០២០ កន្លងទៅ។

❹. សូមអ្នកប្រើប្រាស់ប្រព័ន្ធ FMIS ចូលរួមពង្រឹងគណនេយ្យភាពនៃការប្រើប្រាស់ប្រព័ន្ធ FMIS ដោយធ្វើការពិនិត្យឱ្យបានម៉ត់ចត់លើទិន្នន័យ ដែលបានកត់ត្រាចូលក្នុងប្រព័ន្ធ FMIS និង ប្រើប្រាស់ព័ត៌មានពីប្រព័ន្ធ FMIS ជាគោលសម្រាប់ការគ្រប់-គ្រង និងអនុវត្តថវិកា តាមរយៈការវិភាគតាមដាន ត្រួតពិនិត្យ និងការរៀបចំរបាយ-ការណ៍នានាស្តីអំពីឥណទានថវិកា និងការអនុវត្តថវិកា ដូចជាស្ថានភាពឥណទានថវិកា និងស្ថានភាពចំណូល-ចំណាយ ថវិការបស់ក្រសួង-ស្ថាប័នខ្លួន ដោយប្រើប្រាស់របាយការណ៍ដែលមានស្រាប់នៅក្នុងប្រព័ន្ធ FMIS (Query Reports និង Pre-defined Reports)។

ជាថ្មីម្តងទៀត ខ្ញុំសូមវាយតម្លៃខ្ពស់ និងទទួលស្គាល់ចំពោះការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់, សកម្ម និងបុរេសកម្ម របស់លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS, អគ្គនាយកដ្ឋានសំខាន់ៗនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងបណ្តាក្រសួង-ស្ថាប័នទាំងអស់ ដែលបានធ្វើឱ្យការអនុវត្តគម្រោង FMIS សម្រេចបានតាមគោលដៅនៅក្នុងការអនុវត្តគម្រោង FMIS ជំហានទី២ នេះ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសហភាពអឺរ៉ុបដែលបានផ្តល់នូវថវិកាគាំទ្រ និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី, មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ដែលជាដៃគូដ៏ជិតស្និទ្ធ និងជាអ្នកគាំទ្រដ៏សំខាន់ដល់ការអនុវត្តគម្រោង FMIS នេះ ។

នៅទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ដែលបានចូលរួមនៅក្នុងអង្គពិធីនាពេលនេះ និងសូមជូនពរ មានសេចក្តី-សុខ, សេចក្តីចម្រើន, សុភមង្គល និងសូមប្រកបតែនឹងពុទ្ធពរទាំង៤ ប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ នៅក្រសួង-ស្ថាប័នទាំង ១៧ និងអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១៣ ចាប់ពីពេលនេះតទៅ ៕■

*សូមអរគុណ!*




## ផ្នែកទី ៤

# ទស្សនៈ និងមតិ



សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការកម្មវិធីឧបត្ថម្ភ
សាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេល
ជំងឺកូវីដ-១៩ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

*“ក្រៅពីយន្តការដែលមានស្រាប់ជាអចិន្ត្រៃយ៍នៅថ្នាក់ ឃុំ សង្កាត់ នៅមូលដ្ឋាន, យើងក៏មានក្រុមការងារថ្នាក់ជាតិចុះជួយមូលដ្ឋាន ដើម្បីជួយត្រួតពិនិត្យមើលនូវប្រសិទ្ធភាពនៃការអនុវត្តផងដែរ ។ ហើយសូមឱ្យប្រធានក្រុមការងារនៅគ្រប់ខេត្តទាំងអស់ឆ្លុះបញ្ចាំងឱ្យទាន់ពេលវេលាទៅកាន់ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ដែលជាអ្នកទទួល (គេហៅថា) អគ្គសេនាធិការតែមួយ ព្រោះថាយន្តការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ របស់កម្ពុជា គឺមានអគ្គបញ្ជាការមួយ និងអគ្គសេនាធិការមួយ ។ ក្នុងករណីដែលនាយអគ្គសេនាធិការ គឺរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចដោះស្រាយបាន ក៏បន្តដោះស្រាយទៅ តែបើក្នុងករណីដោះស្រាយមិនបាន ត្រូវស្នើមកអគ្គបញ្ជាការ គឺ នាយករដ្ឋមន្ត្រី ដើម្បីធ្វើកិច្ចការងារទាំងនេះ។ ”*



ប្រសាសន៍ឯកឧត្តមបណ្ឌិតសភាចារ្យ **វង្ស វិសុទ្ធ**
រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

*“ឆ្លើយតបនឹងស្ថានភាព នៃការទប់ទល់វិបត្តិកូវីដ-១៩, ដើម្បីកៀរគរប្រមូលចំណូលឱ្យបានជាអតិបរមាធៀបទៅនឹងច្បាប់ គ្រប់ក្រសួង-ស្ថាប័នប្រមូលចំណូលទាំងអស់ត្រូវប្រកាន់ភ្ជាប់នូវស្មារតីបន្តអនុវត្តវិធានការ និងផែនការសកម្មភាពទាំងឡាយ ដែលបានដាក់ចេញនៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដោយប្រកាន់យកអភិក្រមសម្រួល ឬបន្ធូរបន្ថយចំពោះវិធានការ និងផែនការសកម្មភាពដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលដោយកូវីដ-១៩ និងពង្រឹងការអនុវត្តបន្ថែមទៀតទៅលើវិធានការ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការប្រមូលចំណូលទៅលើវិស័យដែលមិនរងផលប៉ះពាល់ ដើម្បីជាការប៉ះប៉ូវនិងការធ្លាក់ចុះនៃចំណូលថវិកាជាតិ។ ”*



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការកម្មវិធីឧបត្ថម្ភ
សាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេល
ជំងឺកូវីដ-១៩ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

*“ក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការបច្ចេកទេសបំពេញការងារ នៅក្រោមការគ្រប់គ្រង និងចង្អុលដោយផ្ទាល់របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី ក្នុងឋានៈសម្ដេចជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងជាអគ្គមេបញ្ជាការតែមួយក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងសេដ្ឋកិច្ចជាតិ ខ្ញុំសូមគូសបញ្ជាក់ថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ នេះ អាចដាក់ឱ្យ ដំណើរការទៅបាន គឺដោយសារសមិទ្ធផលល្អប្រសើរនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល។ ”*

**EUROPEAN UNION**

មតិរបស់ដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចប្រជុំ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុម
បច្ចេកទេសដៃគូអភិវឌ្ឍន៍ ស្ដីពីការត្រួតពិនិត្យ
វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំ
ឆ្នាំ ២០១៩

*“ដៃគូអភិវឌ្ឍន៍ សូមកោតសរសើរចំពោះរាជរដ្ឋាភិបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) សម្រាប់វឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMRP) ឆ្នាំ ២០១៩ កន្លងមកជាពិសេស លើការកៀរគរចំណូល, ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងថវិកាកម្មវិធី ។ ទៅថ្ងៃខាងមុខ ដៃគូអភិវឌ្ឍន៍សូមលើកទឹកចិត្តឱ្យ កសហវ. ផ្ដោតលើការកែលម្អការគ្រប់គ្រងសាច់ប្រាក់, ការពង្រីកវិសាលភាពនៃចំណាត់ថ្នាក់ថវិកា, ការប្រើប្រាស់ប្រព័ន្ធធនាគារ និងលំហូរហិរញ្ញវត្ថុក្នុងការឆ្លើយតបទៅនឹងគ្រោះអាសន្នបណ្ដាលមកពីជំងឺកូវីដ-១៩ ។ លើសពីនេះ ក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលកម្ពុជាក៏នឹងអាចឆ្លើយតបនឹងភាពអាសន្ន ជាពិសេសការបន្តនិរន្តរភាពការងារការស្ដារសេដ្ឋកិច្ចបន្ទាប់ពីវិបត្តិនានានិងភាពធន់នឹងវិបត្តិសង្គមតាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន។ ”*

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ÷

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ **អ.គ.ហ.** |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង **អ.គ.ហ.** |
| មាស សុខសេនសាន | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង **អ.គ.ហ.** |
| យ៉េត វិណែល | អគ្គលេខាធិការរង **អ.គ.ហ.** |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង **អ.គ.ហ.** |
| អ៊ុង លុយណា | អគ្គលេខាធិការរង **អ.គ.ហ.** |

## រៀបចំអត្ថបទដោយ ÷

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| វុទ្ធី សត្រា | មន្ត្រីជំនាញ |

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លែហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | មន្ត្រីជំនាញ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញជាន់ខ្ពស់ |
| រស់ ដាលីន | មន្ត្រីជំនាញ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ុន | មន្ត្រីជំនាញ |
| ផេង សុខម៉ៃ | មន្ត្រីជំនាញ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីជំនាញជាន់ខ្ពស់ត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យិន ម៉ាលីមឆេង | មន្ត្រីជំនាញជាន់ខ្ពស់ថវិកា |
| ឈុន ម៉ារឌី | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ជា សុផេង | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| អ៊ុង វលក្ខទេវី | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ឡេង ចាន់ភួង | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

ការចូលរួមផ្សេងៗ÷

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## នវានុវត្ត និងកែសម្រួលដោយ ÷

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវរលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |

អាសយដ្ឋានទំនាក់ទំនង÷
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm